ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- មជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យ និងពិគ្រោះយោបល់ផ្នែកសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកអន្លង់វែង
- អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី ៨ ទទួលការបណ្តុះបណ្តាល «ការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំក្នុងដំណើរការអនុវត្តសកម្មភាពការងារស្ម័គ្រចិត្តជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៥ ខែកញ្ញា ឆ្នាំ២០២៣

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៥ ខែកញ្ញា ឆ្នាំ២០២៣

# មាតិកា

## សំបុត្រ

◆ មជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យ និងពិគ្រោះយោបល់ផ្នែកសុខភាពជូនអ្នករស់រាន........... ១

## ផ្នែកឯកសារ

◆ សែល ទេស ៖ ចារបុរស ឡាវ និង យួន......... ៤

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី ៨ ទទួលការបណ្តុះបណ្តាល «ការពង្រីងសមត្ថភាព និងភាពជាអ្នកដឹកនាំ.... ៧
◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ...............១០
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម ក្នុងស្រុកកំពង់សៀម .....................១៣
◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មប្រគេន និងចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ..... ១៦
◆ សាស្ត្រាចារ្យ និស្សិត សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»... ២០
◆ សិស្សានុសិស្សវិទ្យាល័យ ក្រាំងស្វា អាន អំពីព្រឹត្តិការណ៍នៃការយាងមកដល់ប្រទេសកម្ពុជារបស់សម្តេចព្រះនរោត្តម សីហនុ និងព្រះមហា..... ២៣
◆ គុយ ដុង ៖ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»....២៦
◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនលោកគ្រូ.......... ២៨
◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនលោកគ្រូ-អ្នកគ្រូ.. ៣២
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកព្រៃឈរ ទទួលបានសៀវភៅ «សាក្សី......... ៣៥
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម ទទួលបានសៀវភៅ «សាក្សី .... ៣៨
◆ សិស្សានុសិស្សចំនួន ២៤០នាក់ នៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង ទទួលបានសៀវភៅ ......... ៤១
◆ និស្សិតផ្នែកប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញទស្សនកិច្ចមជ្ឈមណ្ឌលឯកសារ ....... ៤៤



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»៖ កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

---

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាពនិងសិទ្ធិមនុស្ស» ......៤៦

## ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាអប់រំស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា....... ៤៩
◆ វេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ...... ៥២

## ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ប្តីខ្ញុំស្លាប់ពេលជម្លៀសទៅបាត់ដំបង ...........៥៥
◆ ស៊ូ យឹម ៖ ខ្ញុំតែងតែនិយាយអំពីការបាត់ខ្លួនរបស់មីងពូ និងរឿងរ៉ាវរបស់ខ្ញុំប្រាប់ទៅកូនចៅ..........៥៦
◆ «ទួលពិឃាដ» (តចប់)........................ ៥៨

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** លី សុខឃាង, ដារ៉ារដ្ឋ មេត្តា, ដេង ពង្សរ៉ាស៊ី, ឡុង ដានី, លី ដេវីត, សាំង ចាន់ធូ, ឈុំ រ៉ា, រឹម ស្រីស្រស់, វី ស៊ីថា, លី ដេវីត, ស៊ាង ចិន្តា, ទូច វណ្ណេត, សួត វិចិត្រ, ថុន ស្រីពេជ្រ, ផន វន្នី និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លឹម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉ាង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# មជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យ និងពិគ្រោះយោបល់ផ្នែកសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកអន្លង់វែង

*លី សុខឃាង*



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំកម្មវិធីពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១០០នាក់ ចាប់ពីថ្ងៃទី៥ ដល់ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ នៅក្នុងវត្តអន្លង់វែង ស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្ដីសោមនស្សរីករាយ ក្នុងការប្រកាសឲ្យដឹងអំពីការពិនិត្យ និងពិគ្រោះយោបល់ផ្នែកសុខភាពដ៏ជោគជ័យសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០០នាក់ ក្នុងចំណោមអ្នករស់រានមានជីវិតនៅថ្នាក់មូលដ្ឋានចំនួន២៦៧ នាក់ នៅស្រុកអន្លង់វែង ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីនេះក្នុងទីតាំងវត្តអន្លង់វែង។ អន្លង់វែងគឺជាតំបន់មួយដែលមានប្រជាជនប្រមាណជាជិត៦ម៉ឺននាក់រស់នៅ ដែលភាគច្រើននៃអ្នកទាំងអស់នោះ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អន្លង់វែង គឺជាសហគមន៍ឆ្ងាយដាច់ស្រយាលមួយដែលមានទីតាំងស្ថិតនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ដែលតំបន់នេះត្រូវបានគេស្គាល់ជាទូទៅថាជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម។ តំបន់នេះមានអត្រា



មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំកម្មវិធីពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១០០នាក់ ចាប់ពីថ្ងៃទី៥ ដល់ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ នៅក្នុងវត្តអន្លង់វែង ស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភាគរយខ្ពស់នៃប្រជាជនដែលត្រូវបានចាត់ទុកថាជាអ្នកដែលមានជីវភាពក្រីក្រ ដោយសារតំបន់នេះគឺជាតំបន់តស៊ូដ៏សំខាន់មួយ ដូច្នេះហើយបានជាភាគរយជាមធ្យមនៃប្រជាជនគឺទទួលរងនូវពិការភាព។ ដោយសារតែភាពក្រីក្រ និងពិការភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងអស់នេះ ការទទួលបាននូវការថែទាំសុខភាពត្រូវបានចាត់ទុកថាជាបញ្ហាប្រឈមដ៏សំខាន់បំផុតរបស់សហគមន៍នេះ។ វាមិនមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេដែលថាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនបានលើកឡើងនៅក្នុងការស្ទាបស្ទង់មតិនេះ គឺថាខ្លួនមិនសូវយកចិត្តទុកដាក់ចំពោះបញ្ហាសុខភាពទេ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្តីរំភើបរីករាយ ក្នុងការបញ្ជូនក្រុមយុវជនស្ម័គ្រចិត្តដើម្បីពង្រីកនូវសេវាកម្ម និងការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងរបៀបមួយប្រកបដោយប្រសិទ្ធភាព។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាត់បញ្ជូនក្រុមអ្នកស្ម័គ្រចិត្តនេះដើម្បីជួបអ្នករស់រានមានជីវិត និងក្រុមគ្រួសាររបស់ពួកគាត់។ យុវជនស្ម័គ្រចិត្តទាំងអស់នេះបានធ្វើការស្ទាបស្ទង់មតិផ្នែកសុខភាព ប្រមូលរឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ហើយបានផ្តល់នូវព័ត៌មានសង្ខេបគ្រួសៗអំពីស្ថានភាពសុខភាពសាធារណៈដែលកើតឡើងច្រើនចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

មានប្រជាជនមូលដ្ឋានប្រមាណ២៦៧ នាក់ដែលយល់ព្រមផ្តល់នូវព័ត៌មានស្តីអំពីស្ថានភាពសុខភាព, បញ្ហា និងប្រធានបទទាក់ទងរបស់ខ្លួន។ ប្រជាជនទាំង២៦៧ នាក់នេះត្រូវបានស្ទាបស្ទង់មតិ ហើយប្រជាជន១០០នាក់ត្រូវបានជ្រើសរើសក្នុងការទទួលបាននូវការពិគ្រោះ និងពិនិត្យសុខភាពនេះ។ ការស្ទាបស្ទង់មតិនេះ ក៏បានរាប់បញ្ចូល ទាំងសំណួរអំពីបទពិសោធន៍រឿងរ៉ាវជីវិតដែលមិនអាច









មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំកម្មវិធីពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១០០នាក់ ចាប់ពីថ្ងៃទី៥ ដល់ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ នៅក្នុងវត្តអន្លង់វែង ស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បំភ្លេចបានរបស់អ្នករស់រានមានជីវិតនៅក្រោមរបបខ្មែរក្រហម និងមានសំណួរជាច្រើនដែលពាក់ព័ន្ធនឹងស្ថានភាពសុខភាពក្នុងចំណោមប្រធានបទផ្សេងៗទៀត។ ក្រៅពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែធ្វើបទសម្ភាសន៍ជាមួយក្រុមគ្រួសាររបស់ពួកគេ ក្នុងគោលបំណងដើម្បីឈ្វេងយល់អំពីបណ្ដាញដើម្បីឲ្យមានការគាំទ្រដល់អ្នករស់រានមានជីវិតទាំងអស់នេះដែរ។ លទ្ធផលនៃការស្ទាបស្ទង់មតិបានបង្ហាញឲ្យឃើញថា អ្នកឆ្លើយទៅនឹងការស្ទាបស្ទង់មតិនេះនៅចន្លោះអាយុពី៥០ឆ្នាំ ដល់ ៨៩ឆ្នាំ កំពុងប្រឈមទៅនឹងជំងឺយ៉ាងហោចណាស់ក៏១០មុខ ឬស្ថានភាពជំងឺរ៉ាំរ៉ៃ ដែលមានភាពស្របគ្នាជាមួយនឹងការឆ្លើយតបរបស់អ្នករស់រានមានជីវិតជាច្រើនផ្សេងទៀត នៅក្នុងផ្នែកផ្សេងៗទៀតនៃប្រទេសដែរ។ ស្ថានភាពពីរសំខាន់ដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានលើកឡើងនោះគឺ ជំងឺក្រពះពោះវៀន (ស្ថិតនៅក្នុងលំដាប់ទី១) បន្ទាប់មកគឺជំងឺលើសសម្ពាធឈាម។

វាហាក់ដូចជាថា នៅក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២៦៧ នាក់ ដែលត្រូវបានស្ទង់មតិនេះ គឺមានអ្នករស់រានមានជីវិតចំនួន១២៧ នាក់មានជំងឺក្រពះពោះវៀន។ ជាការគួរឲ្យកត់សម្គាល់ ជំងឺសុខភាពផ្លូវចិត្តបានស្ដែងឲ្យឃើញថា ស្ថិតនៅក្នុងស្ថានភាពជំងឺទូទៅទី៥ និងជំងឺឆ្កួតជ្រូកត្រូវបានកំណត់សម្គាល់ថាជាជំងឺទូទៅបំផុត ឬហៅថាជំងឺទី១០ក្នុងចំណោមការស្ទាបស្ទង់មតិទាំងអស់នេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានមោទនភាពអំពីជោគជ័យនៃការរៀបចំការពិគ្រោះ និងពិនិត្យសុខភាពនេះ ព្រមទាំងសង្ឃឹមថានឹងអនុវត្តសកម្មភាពនេះនៅតាមភូមិផ្សេងៗទៀតក្នុងតំបន់នេះ ឬនៅស្រុកឆ្ងាយដាច់ស្រយាលផ្សេងៗទៀតនៅតាមបណ្ដោយព្រំដែន។

# សែល ទេស ៖ ចារបុរសឡាវ និង យួន

ដារ៉ារដ្ឋ មេត្តា



កងទ័ពបដិវត្តន៍ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សែល ទេស អាយុ៦២ឆ្នាំ (ក្នុងឆ្នាំ១៩៧៨)។ ខ្ញុំមានស្រុកកំណើតនៅ ភូមិតាអុយ ឃុំក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ។ នៅពេលខ្ញុំមានអាយុ១៨ឆ្នាំ ខ្ញុំបួសនៅវត្តព្រៃគុយ ស្ថិតនៅក្នុងខេត្តតាកែវ និងវត្តប្រលោម ទីក្រុងភ្នំពេញ អស់រយៈពេល១៨ឆ្នាំ។ បន្ទាប់ពីខ្ញុំមានអាយុ២៦ឆ្នាំ ខ្ញុំបានលាចាកសិក្ខាបទ។ នៅក្នុងឆ្នាំ១៩៤៦ ឈ្មោះ តែម គឺជាតំណាងរាស្ត្រនៅស្រុកកោះអណ្តែត បានមកឃោសនាឲ្យប្រជាជនទាំងអស់ជួយបោះឆ្នោតឲ្យគណបក្សប្រជាធិបតេយ្យដែលមានរូប «ក្បាលដំរី» ដោយឃោសនាធានាជួយរកការងារឲ្យប្រជាជនធ្វើ។ ពេលនោះខ្ញុំបានបោះឆ្នោតឲ្យគណបក្សប្រជាធិបតេយ្យដែលមានលោក អៀវ កើស គឺជាបេក្ខភាពឈរឈ្មោះឲ្យប្រជាជនបោះឆ្នោត។ ក្រោយការបោះឆ្នោតបានរយៈពេល២ឆ្នាំ នៅក្នុងស្រុកភូមិខ្ញុំជួបគ្រោះរាំងស្ងួតធ្វើស្រែមិនបាន។ ខ្ញុំក៏មករកស៊ីលក់ដូរនៅភ្នំពេញ ហើយពេលនោះខ្ញុំបានជួប តែម ម្តងទៀតនៅជិតផ្សារថ្មី។ តែម បាននាំខ្ញុំទៅជួបលោក អៀវ កើស គឺជាតំណាងរាស្ត្រនៅមណ្ឌលថ្មីដែលផ្ទះគាត់នៅជិតឃ្លាំងប្រាក់ និងមានឈ្មោះ ង៉ែត ហ៊ាន គឺជាតំណាងរាស្ត្រមណ្ឌលស្ពានកូនកាត់ភ្នំពេញ។ ក្រោយមកឈ្មោះទាំង៣នាក់នេះបានអប់រំ

ខ្ញុំឲ្យជួយធ្វើការឲ្យគាត់។ ពេលនោះហើយដែលខ្ញុំចូលជាសមាជិកខ្មែរសេរី។ អ្នកចូលជាមួយខ្ញុំឈ្មោះ ង៉ែត ខួយ អតីតធ្វើគិញនៅនគរបាលជាតិផ្សារថ្មី។ នៅក្នុងកម្មវិធីបញ្ចូលបក្សមានការគោរពរូបថតព្រះអង្គម្ចាស់ យុត្តិវង្ស គឺជាអ្នកចម្លងរដ្ឋធម្មនុញ្ញ និងជាអ្នកបង្កើតបក្សខ្មែរសេរី ដោយមានការស្បថសច្ចាប្រណិធាន។

នៅឆ្នាំ១៩៥៩ ឈ្មោះ យុត គឺជាអ្នកបើកបរឡានឲ្យឈ្មោះ ឡាវ ភ៉ារី ជនជាតិបារាំងនៅស្រុកឡាវ ដែលរស់នៅភូមិជាមួយខ្ញុំបានយកខ្ញុំទៅដើរឡានជាមួយនៅស្រុកឡាវ ខេត្តប៉ាកសេ។ រហូតដល់ឆ្នាំ១៩៦៣ ខ្ញុំឈប់នៅជាមួយបារាំង ឡាវ ភ៉ារី ដោយខ្ញុំចេញទៅរកស៊ីនៅក្នុងក្រុមហ៊ុន ខាងសំណង់របស់បារាំងឈ្មោះ សិចក្លូក។ ក្រោយមកនៅក្នុងឆ្នាំ១៩៦៤ ខ្ញុំចេញពីឈ្មោះ សិចក្លូក ទៅរកស៊ីធ្វើជាងផ្ទះនៅក្នុងសុវណ្ណខេត មានឈ្មោះ ភឹម គឺជាជនជាតិខ្មែរ និង ឈ្មោះ ង្វៀនធីបា ជនជាតិយួន គឺជាម្ចាស់ក្រុមហ៊ុនជាមួយគ្នា។ នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំឡើងទៅក្រុងវៀងចន្ទន៍ ទាក់ទងជាមួយឈ្មោះ ម៉ឺនសៀក្លាម៉ង់ គឺជាអ្នកជំនួញជនជាតិបារាំង។ ពេលនោះខ្ញុំធ្វើជាអ្នកយាមឃ្លាំង រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ទើបខ្ញុំចូលមកប្រទេសកម្ពុជា។

## អំពីសភាពការណ៍ ឡាវ ចាត់តាំងចូលដីកម្ពុជា

នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៥ ខ្ញុំទាក់ទងជិតស្និទ្ធជាមួយឈ្មោះ ភោនទោ គឺជាសក្តិ៣ ទាហានប៉ាឡាវ ហើយបច្ចុប្បន្នគឺជាអ្នកបើកឡានឲ្យ កៃសន កុមវិហាន គឺជានាយករដ្ឋមន្ត្រី ឡាវ។ មុនដំបូងខ្ញុំមានការទាក់ទងស៊ីជីកជាមួយ ភោនទោ ហើយគាត់បានលើកឡើងអប់រំពន្យល់អំពីគោលការរបស់រដ្ឋាភិបាល ឡាវ និង យួន។

នៅខែឧសភា ឆ្នាំ១៩៧៧ ភោនទោ នាំខ្ញុំទៅជួបជាមួយ អុង ហឿង សក្តិ៥យួន ដែលបោះមូលដ្ឋានទ័ពនៅ ទីរួមខេត្ត ប៉ាកសេ ក្នុងទឹកដីឡាវ នៅទល់មុខស្រុកវ៉ឺនសៃ ចម្ងាយពីព្រំដែនប្រហែលជា២០គីឡូម៉ែត្រដើម្បីឲ្យឃើញពីកម្លាំងទ័ពយួននិងសម្ភាររបស់កងទ័ពយួន។ នៅពេលនោះ អុង ហឿង បានធ្វើពិធីជប់លៀងហើយ អុង ហឿង បានអាដៃយកឈាមលាយទឹកឲ្យខ្ញុំផឹកដើម្បីសច្ចាវ៉ាង មិត្តភាពយើងទាំង៣នាក់។ ក្រោយពីមើលទ័ពយួនរួច ភោនទោ បាននាំខ្ញុំទៅជួបជាមួយ មាស ខាំ សក្តិ៥ ឡាវដែលបោះមូលដ្ឋានទ័ពនៅប៉ាកសេ ដើម្បីឲ្យទៅមើលកងទ័ពរបស់ ឡាវនៅកន្លែងនោះទៀត។

នៅខែតុលា ឆ្នាំ១៩៧៧ ភោនទោ បាននាំខ្ញុំទៅប្រជុំទទួលផែនការនៅបន្ទាយ មឿង ខុង ហើយអ្នកដាក់ផែនការឲ្យមាន អុង ហឿង, មាស ខាំ និង ភោនទោ។ ពេលយួនដាក់ផែនការលើកទីមួយឲ្យចូលប្រទេសកម្ពុជានៅក្នុងអំឡុងឆ្នាំ១៩៧៧ ប៉ុន្តែមិនបានសម្រេច។ ដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ ភោនទោ បានហៅខ្ញុំទៅណែនាំដាក់ផែនការឲ្យចូលមកកម្ពុជាម្តងទៀត។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ខ្ញុំបានចូលមកប្រទេសកម្ពុជា ហើយក្រោយមកនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៨ អង្គការចាប់ខ្ញុំមកសួរចម្លើយ។

## អំពីផែនការរបស់ ឡាវ និង យួន

ខ្ញុំត្រូវបានចាត់តាំងមកកម្ពុជា ហើយពេលមកដល់ត្រូវទាក់ទងស្នើសុំរដ្ឋាភិបាលកម្ពុជាឲ្យទៅនៅស្ទឹងត្រែងឲ្យបានដើម្បីក្តាប់សភាពការណ៍នៅកម្ពុជា តើមានកងទ័ពប៉ុន្មាននាក់នៅស្ទឹងត្រែង និងខេត្តរតនគិរី, ស៊ើបរកព័ត៌មាន សៀម និងយួន វាយជាមួយកម្ពុជាជាប់គ្នាឬទេ? បើជាប់វាយគ្នាឲ្យខ្ញុំទៅរាយការណ៍ឲ្យគេ ដើម្បីចាត់តាំងទ័ពសម្ងាត់វាយយកខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ,ឲ្យរកផែនទីដែលជាឯកសារយុទ្ធសាស្ត្រនៅស្ទឹងត្រែងឲ្យបានយកទៅឲ្យគេ, ពិនិត្យមើលសភាពការណ៍នៅស្រុកសៀមប៉ាង, ស្រុកវ៉ឺនសៃ តាមផ្លូវគីឡូ៩០ ទៅខេត្តរតនគិរី តើមានកងទ័ពខ្មែរច្រើនឬទេ? តើមានបន្ទាយទាហានធំៗឬទេ នៅរតនគិរី និងនៅស្រុកសៀមប៉ាង? តើមានកងទ័ពនៅបន្ទាយចាស់ឬទេ? ពិនិត្យមើលកងទ័ព សម្ភារ យោធាខ្មែរមានអ្វីខ្លះ? ត្រូវចេញទៅរាយការណ៍ឲ្យ អុង ហឿង, មាស ខាំ

និង ភោនទោ ដឹងដើម្បីនាំកងទ័ពឡាវ យួន ចូលវាយនៅស្រុកវ៉ិនសៃ, សៀមប៉ាង ខេត្តស្ទឹងត្រែង រហូតដល់អូរគ្រាំង ខេត្តក្រចេះ។

## ស្ថានភាពបច្ចុប្បន្ននៅប្រទេសឡាវ (នៅក្នុងឆ្នាំ១៩៧៨)

ប្រជាជនឡាវនៅរកស៊ីឯកជនមួយសប្តាហ៍ធ្វើការឲ្យរដ្ឋមួយថ្ងៃ, នៅមានផ្សារលក់ដូរជាធម្មតា បន - បារ ក៏នៅបើកដំណើរការ, សភាពការណ៍ប្រជាជនអត់បាយ, សៀមផ្តាច់សេដ្ឋកិច្ចប្រទេសឡាវជាពិសេសបញ្ហាប្រេងឥន្ធនៈ។ ប្រទេសវៀតណាមក៏សង្កត់កឡាវៗ បច្ចុប្បន្នកងទ័ពវៀតណាមមានចំនួន៦ម៉ឺននាក់ នៅប្រទេសឡាវ, ចំណែកភាពអសន្តិសុខនៅក្នុងប្រទេស ក្រុមស្តាំនិយមឡាវនៅតែបន្តចូលអុកឡុកជាប់នៅតំបន់ប៉ាកសាន ប៉ាកសេ ក្រេតក្រត ហើយវៀតណាមមិនបង្ក្រាបឡើយ ប៉ុន្តែវៀតណាមស្នើឲ្យរដ្ឋាភិបាលឡាវបន្ថែមកងទ័ពវៀតណាមទើបការពារបាន។

## សភាពការណ៍ក្រុមស្តាំនិយមឡាវទាក់ទងសៀម

នៅក្នុងឆ្នាំ១៩៧៦ ក្រុមស្តាំនិយមឡាវបើកផ្លូវឲ្យប្រជាជននៅលើកោះខាងមុខទីក្រុងវៀងចន្ទន៍ចូលទៅប្រទេសសៀម។ ប្រទេសឡាវកំពុងពង្រីកព្រលានយន្តហោះឲ្យធំ ចម្ងាយប្រមាណ៣គីឡូម៉ែត្រពីក្រុងវៀងចន្ទន៍ ដែលជាផែនការរបស់សូវៀតឲ្យយន្តហោះចំនួន ២គ្រឿង មកឡាវ។ កងទ័ពឡាវបច្ចុប្បន្នមិនធ្វើការអ្វីទេ ហើយយុវជនឡាវបច្ចុប្បន្នរៀនភាសារុស្ស៊ី។ នៅតាមរោងចក្រប៉ែកខាងត្បូងក្រុងវៀងចន្ទន៍ វៀតណាម គឺជាអ្នកកាន់កាប់ការងារខាងបច្ចេកទេស ហើយនៅខាងថា ង៉ែន ខាងកើតចម្ងាយប្រមាណ ២០គីឡូម៉ែត្រ ពីក្រុងវៀងចន្ទន៍ មានជនជាតិជប៉ុន គឺជាអ្នកដឹកនាំខាងបច្ចេកទេសធ្វើស្រែ ហើយនៅណាមងើម គឺជាកន្លែងប្រព័ន្ធវារីអគ្គិសនី នៅខាងជើងក្រុងវៀងចន្ទន៍ ក៏មានជប៉ុនទទួលខាងបច្ចេកទេសដែរ។ នៅក្នុងផ្សារនីមួយៗ នៅក្នុងទីក្រុងវៀងចន្ទន៍ មានប្រជាជនវៀតណាមមានចំនួន៦០ភាគរយ ហើយមន្ទីរពេទ្យរបស់ឡាវឥឡូវមានជនជាតិវៀតណាមធ្វើការស្ទើរទាំងអស់។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០០៨០។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់សែល ទេស ពិតប្រយ៉ាងណានោះទេ?**



យុទ្ធនារីបដិវត្តន៍ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី ៨ ទទួលការបណ្តុះបណ្តាល

## «ការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំក្នុងដំណើរការអនុវត្តសកម្មភាពការងារស្ម័គ្រចិត្តជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»

ផេង ពង្សរ៉ាស៊ី



អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន១៣៥នាក់ក្នុងនោះស្រីចំនួន ១០៣នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលបួនថ្ងៃ គឺចាប់ពីថ្ងៃទី៨ ដល់ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមប្រធានបទ «ការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំក្នុងដំណើរការអនុវត្តសកម្មភាពការងារជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន ១៣៥នាក់ ក្នុងនោះស្រីចំនួន១០៣នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលបួនថ្ងៃគឺចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមប្រធានបទ «ការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំក្នុងដំណើរការអនុវត្តសកម្មភាពការងារជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បណ្តុះស្មារតីឲ្យមានភាពជាអ្នកដឹកនាំ និងយល់អំពីវិធីសាស្ត្រជាក់លាក់ក្នុងការចុះទៅអនុវត្តសកម្មភាព

ការងារនៅតាមមូលដ្ឋានៗ ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើនេះ វគ្គបណ្តុះបណ្តាល បានអនុវត្តតាមរបៀបវារៈសំខាន់ៗមួយចំនួន ដូចជា ១) បទបង្ហាញលម្អិតពីបរិបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ២) ណែនាំពីគន្លឹះចាំបាច់មួយចំនួនក្នុងការចុះអនុវត្តសកម្មភាពការងារនៅតាមមូលដ្ឋាន, ៣) វេទិកាពិភាក្សាអំពីវិធីសាស្ត្រសម្ភាសន៍ឥរិយាបទរបស់អ្នកសម្ភាសន៍ និងសរសេរសេចក្តីសង្ខេប និង ៤) ណែនាំពីការប្រមូល និងថែរក្សាទិន្នន័យតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។ ដើម្បីឈានទៅសម្រេចបាននូវរបៀបវារៈទាំង៤នេះ អ្នកស្ម័គ្រចិត្តកម្ពុជាបានចំណាយពេលវេលាជាង៦ម៉ោង ក្នុងការទទួលបានគ្រប់ចំណុចនៃរបៀបវារៈដែលបានកំណត់ៗ

## ការជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ព័ត៌មានស្តីពីការជ្រើសរើសអ្នកស្ម័គ្រចិត្ត

នៅខែកក្កដា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានប្រកាសព័ត៌មានស្តីពីការជ្រើសរើសអ្នកស្ម័គ្រចិត្តចេញពីមូលដ្ឋាននានាក្នុងស្រុកព្រៃកប្បាស ស្រុកត្រាំកក់ ស្រុកបូរីជលសារ និងស្រុកបាទីៗ សេចក្តីប្រកាសព័ត៌មាន ត្រូវបានបិទនៅតាមសាលាឃុំ វិទ្យាល័យ សាកលវិទ្យាល័យ បៀលប្រាយសាខាខេត្តតាកែវ ការិយាល័យអប់រំស្រុក និងតាមរយៈការពិភាក្សា និងផ្លាស់ប្តូរយោបល់ជាមួយមន្ត្រីនៅសាលាស្រុកៗ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ សូមថ្លែងអំណរគុណដល់ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានទាំងអស់ ដែលបានផ្តល់ការសម្របសម្រួល និងសហការខ្ពស់ក្នុងការបំពេញកិច្ចការងារនេះៗ

## ប្រវត្តិរូបសង្ខេប និង ចំណាប់អារម្មណ៍ការងាររបស់អ្នកស្ម័គ្រចិត្ត

នៅដើម ខែសីហា ឆ្នាំ២០២៣ ដដែល មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានទទួលពាក្យស្នើសុំធ្វើជាអ្នកស្ម័គ្រចិត្តចំនួន១០២នាក់ មកពីស្រុកព្រៃកប្បាស ស្រុកត្រាំកក់ ស្រុកបូរីជលសារ និងស្រុកបាទី ហើយនៅសប្តាហ៍ទីបី ខែសីហា ដដែល អ្នកដាក់ពាក្យស្នើសុំ កើនរហូតដល់១៣៥នាក់ៗ អ្នកទាំងនេះបានផ្ញើប្រវត្តិរូប និងចំណាប់អារម្មណ៍ធ្វើជាអ្នកស្ម័គ្រចិត្តកម្ពុជា ពីចម្ងាយតាមរយៈប្រព័ន្ធតេឡេក្រាម និងមកកាន់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវផ្ទាល់ៗ ប្រវត្តិរូបដែលបានដាក់មក យើងសង្កេតឃើញមានភាគច្រើនគឺជាសិស្សានុសិស្សនៅកម្រិតវិទ្យាល័យ និងភាគតិចគឺជានិស្សិតដែលបានបញ្ចប់ការសិក្សា និងកំពុងសិក្សានៅសាកលវិទ្យាល័យៗ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំ និងទុកដាក់ឯកសារ ទាំងនោះយ៉ាងត្រឹមត្រូវសម្រាប់ការប្រើប្រាស់ក្នុងផ្នែករដ្ឋបាលនាពេលក្រោយៗ

អ្នកស្ម័គ្រចិត្ត បំពេញកម្រងសំណួរស្តីពីការវាយតម្លៃបុគ្គលិកលក្ខណៈរបស់អ្នកស្ម័គ្រចិត្ត (រយៈពេល៣០នាទី) កិច្ចចាប់ផ្តើមវគ្គបណ្តុះបណ្តាលនៅថ្ងៃទីមួយៗ អ្នកស្ម័គ្រចិត្តត្រូវបានណែនាំឲ្យបំពេញកម្រងសំណួរចំនួន៤ទំព័រ រួមមានសំណួរស្តីអំពី៖

១) អត្តចរិតរបស់អ្នកស្ម័គ្រចិត្ត (មាន៣សំណួរ), ២) ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកស្ម័គ្រចិត្ត និងព័ត៌មានទាក់ទងនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (មាន៣សំណួរ), ៣) អំពីកិច្ចការផ្នែកសុខភាព (មាន៦សំណួរ), និង៤) អំពីការប្តេជ្ញាចិត្តលះបង់ពេលវេលារបស់អ្នកស្ម័គ្រចិត្តចំពោះកិច្ចការនៅតាមមូលដ្ឋាន (មាន៣សំណួរ)ៗ ការចំណាយពេលវេលាដើម្បីឆ្លើយទៅនឹងសំណួរខាងលើ គឺជាការចំណាយពេលវេលាគិតគូរច្បាស់លាស់សម្រាប់អ្នកស្ម័គ្រចិត្តម្នាក់ៗ មុននឹងសម្រេចចិត្តធ្វើជាអ្នកស្ម័គ្រចិត្តកម្ពុជាៗ សំណួរទាំងអស់ដែលមាននៅក្នុងកម្រងសំណួរ គឺដើម្បីវាស់ស្ទង់ពីសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់ខ្លួន ក្នុងការបំពេញភារកិច្ចជាអ្នកស្ម័គ្រចិត្តកម្ពុជានៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវៗ

លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានពន្យល់ដល់អ្នកចូលរួម ទាំងអស់ពីសារសំខាន់កិច្ចការស្ម័គ្រចិត្ត និងផលប្រយោជន៍ដែលទទួលបានពីការធ្វើកិច្ចការងារនេះថា អ្នកស្ម័គ្រចិត្តនឹងទទួលបាន៖ ១) បទពិសោធន៍ធ្វើការងារសង្គមជាមួយអ្នករស់នៅក្នុងភូមិឃុំជាមួយខ្លួន ២) បង្កើនសមត្ថភាពលើជំនាញទំនាក់ទំនងជាសាធារណៈ ភាពជាអ្នកដឹកនាំ និងការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តកិច្ចការដោយឯករាជ្យ ៣) មានសមត្ថភាពក្នុងការឈ្វេងយល់បន្ថែមពីមាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ៤) ទទួលបានការស្ញប់ស្ញែង និងកោតសរសើរពីមនុស្សដែលនៅជុំវិញខ្លួនចំពោះកិច្ចការងារសង្គម ៥) មានទម្លាប់ល្អក្នុងការប្រើប្រាស់ពេលវេលាទំនេរពីការសិក្សា មកធ្វើកិច្ចការងារបម្រើសង្គម និងប្រទេសជាតិ និង ៦) មានឱកាសច្រើនក្នុងការចូលបម្រើកិច្ចការងារដែលខ្លួនចង់ធ្វើនាពេលអនាគតតាមរយៈបទពិសោធន៍ជាអ្នកស្ម័គ្រចិត្ត។

អ្នកស្ម័គ្រចិត្ត ឈ្វេងយល់ពីគម្រោងស្តីពី «ការលើកកម្ពស់សិទ្ធិនិងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (រយៈពេល៥នាទី) បន្ទាប់មក លោក ផេង ពង្សរ៉ាស៊ី បានបង្ហាញដល់អ្នកស្ម័គ្រចិត្តទាំងអស់ពីឈ្មោះគម្រោង និងពីគោលបំណងរបស់គម្រោងដែលផ្តោតលើចំណុចសំខាន់មួយចំនួនគឺ៖ ១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ តាមរយៈការអន្តរាគមន៍ដែលមានគោលដៅសំដៅទៅដល់ការលើកកម្ពស់ការយល់ដឹងពីសុខភាពសាធារណៈ និងការទទួលបានសេវាសុខភាពសាធារណៈ ២) ស្រាវជ្រាវអំពីស្ថានភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការនៅតាមសហគមន៍ដាច់ស្រយាល សម្រាប់ជាព័ត៌មានក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជន និងសហគមន៍ទាំងនោះ។












អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន១៣៥នាក់ក្នុងនោះស្រីចំនួន១០៣នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលបួនថ្ងៃ គឺចាប់ពីថ្ងៃទី៨ ដល់ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមប្រធានបទ «ការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំក្នុងដំណើរការអនុវត្តសកម្មភាពការងារជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែក សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ

## របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន

ឡុង ដានី



នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ដល់សិស្សានុសិស្សវិទ្យាល័យ ហ៊ុនសែនបាក់ចិញ្ចៀន ស្ថិតនៅក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង រួមមាន ឡុង ដានី, ឡុង អូន, ធី គីមហុង និង ចាន់ ណារិទ្ធ បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន១០០នាក់ ក្នុងនោះមានស្រី៦៤នាក់ នៅវិទ្យាល័យ ហ៊ុនសែន បាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

មុនពេលចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុ-សិស្ស លោកគ្រូ ស៊ុំ ដារិទ្ធ នាយកវិទ្យាល័យ

ហ៊ុន សែន បាក់ចិញ្ចៀន បានទទួលស្វាគមន៍ និងមានប្រសាសន៍ថា ថ្ងៃនេះវិទ្យាល័យ ហ៊ុន សែន បាក់ចិញ្ចៀន មានសេចក្ដីរីករាយដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មកចែកជូនលោកគ្រូ អ្នកគ្រូសិស្សានុសិស្ស នៅវិទ្យាល័យយើងខ្ញុំ។ លោកគ្រូ ស៊ុំ ដារិទ្ធ ក៏បានផ្ដាំផ្ញើសិស្សានុសិស្សទាំងអស់ឲ្យយកចិត្តទុកដាក់អានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ពីព្រោះសៀវភៅនេះមានសារសំខាន់ និងជាជំនួយបន្ថែមនៅពេលប្អូនៗសិក្សាមុខវិទ្យាប្រវត្តិសាស្ត្រអំពីប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍។

បន្ទាប់មក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានណែនាំខ្លួន និងក្រុមការងារដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ លោក ឡុង ដានី បានជម្រាបថា មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចាប់ផ្ដើមដំណើរការនៅថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២៣។ ការិយាល័យមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ស្ថិតនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ការបើកដំណើការមជ្ឈមណ្ឌលផ្សះផ្សាវាលវែងមានគោលបំណងដូចខាងក្រោម៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រនិងសង្គ្រាមនៅប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៩០។

២) ពង្រឹងការកសាងសន្តិភាព និងទប់ស្កាត់ជម្លោះតាមរយៈកម្មវិធីអប់រំជាឱកាសចូលរួមសម្រាប់យុវជនរស់នៅតំបន់ជនបទ និង តំបន់ដាច់ស្រយាល។

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែក និងបង្រៀនក្មេងៗនូវបទពិសោធន៍ របស់ពួកគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។

៤) ប្រមែប្រមូលចងក្រងទីតាំងប្រវត្តិសាស្ត្រ យោធា និងរឿងរ៉ាវបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

៥) ជួយសម្របសម្រួលលើគម្រោង «ការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា»។

ជាចុងក្រោយ លោក ឡុង ដានី បានបន្ថែមថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះ គឺជាព្រះរាជសំណេរដើម និងមិនបានកែសម្រួល ដោយឆ្លុះបញ្ចាំងអំពីព្រះរាជគម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់សម្ដេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព និងសេចក្ដីថ្លៃថ្នូរក្នុងអំឡុងពេលដែលព្រះអង្គអមព្រះរាជដំណើរ សម្ដេច





នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ដល់សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែនបាក់ចិញ្ចៀន ស្ថិតនៅក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ តាមយន្តហោះចេញពីទីក្រុងប៉េកាំងទៅកាន់ទីក្រុងហាណូយ និងទីក្រុងដុងហ៊ូយ ខេត្តក័ងប៊ិញនៃ ប្រទេសវៀតណាម និងយានបន្តដោយរថយន្តតាមបណ្តោយផ្លូវលំហូជីមិញទៅកាន់ខេត្តសៀមរាប ប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៣។ ព្រះរាជដំណើររបស់ព្រះអង្គត្រូវចំណាយពេលជាងមួយខែនេះ បានបង្ហាញយ៉ាងច្រើនពីសេចក្តីថ្លៃថ្នូរ និងភាពទន់ភ្លន់របស់ព្រះមហាក្សត្រី ទោះជាព្រះរាជដំណើររបស់ព្រះអង្គស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍នាពេលនោះក្តី។ ព្រះមហាក្សត្រី គឺជាសាក្សីផ្ទាល់ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងរយៈកាលជាង៧ទសវត្សរ៍កន្លងមក ហើយព្រះអង្គគឺជាឥស្សរជនប្រវត្តិសាស្ត្រដ៏លេចធ្លោមួយព្រះអង្គក្នុងអំឡុងពេលនោះ។ ព្រះរាជសំណេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ទ្រង់ ផ្តល់នូវព្រះរាជគម្រិះសង្ខេបអំពីជំពូកដ៏សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្ស៖

**ភួង លីណា** ៖ «នាងខ្ញុំសប្បាយរីករាយខ្លាំងណាស់ដែលខាងមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះមកចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុរបស់ហ្លួងម៉ែដល់រូបនាងខ្ញុំ។ ខ្ញុំនឹងអានសៀវភៅនេះឲ្យចប់ ដើម្បីបានយល់ដឹងអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។

**ជុំ ម៉ុនថេង** ៖ «ខ្ញុំពិតជាពេញចិត្តនិងសប្បាយរីករាយចំពោះក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុរបស់ហ្លួងម៉ែ។ ខ្ញុំនឹងបានយល់ដឹងអំពីទីតាំងភូមិសាស្ត្រ និងស្ថានភាពរបស់ប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍នៅអំឡុងពេលនោះ។



នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ដល់សិស្សានុសិស្សវិទ្យាល័យហ៊ុន សែនបាក់ចិញ្ចៀន ស្ថិតនៅក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម ក្នុងស្រុកកំពង់សៀម និង ស្រុកកោះសូទិន ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

## កំណាត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

*លី ដេវីត និង សាំង ចាន់ធូ*



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម ក្នុងភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន និងភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចំនួន១០០នាក់ ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក ស៊ាង ចិន្តា, ទូច វណ្ណេត, សាំង ចាន់ធូ និង លី ដេវីត បានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម សរុបចំនួន១០០នាក់ នៅក្នុងភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន និងភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម ក្នុងភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន និងភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចំនួន១០០នាក់ ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងឱកាសចុះជួប និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅសហគមន៍ចាម លោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានបង្ហាញសេចក្ដីរីករាយ និងលើកឡើងអំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរ និងជាស្នាព្រះហស្តផ្ទាល់របស់ហ្លួងម៉ែ ក្នុងព្រះរាជដំណើរអមព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ មកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» មិនត្រឹមតែផ្ដល់ចំណេះដឹងទាក់ទងប្រវត្តិសាស្ត្រកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដល់ការឆ្លុះបញ្ចាំងអំពីរឿងរ៉ាវ ដែលបានកើតឡើងនៅមូលដ្ឋានឃុំគគរ និងឃុំកោះសូទិន ក្នុងអំឡុងពេលនោះដែរ។ បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ប្រជាជននៅសហគមន៍ចាម នាំគ្នាអាននិងពិភាក្សាគ្នាអំពីបទពិសោធន៍ដែលខ្លួនបានឆ្លងកាត់សម័យកាលសង្គ្រាម និងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម ចែករំលែកនូវការចងចាំរបស់ខ្លួនអំពីបទពិសោធន៍លំបាកលំបិន និងការបាត់បង់សមាជិកគ្រួសារក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហមដូចខាងក្រោម ៖

**ម៉ាត់ ទី** អាយុ៦៣ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន រំឭកអំពីបទពិសោធន៍របស់ខ្លួនក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហមថា «ខ្ញុំឈ្មោះ ម៉ាត់ ទី កើតនៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន។ កាលពីក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាចុងកោះ។ នៅឆ្នាំ១៩៧១ ខ្ញុំឈប់រៀន ពីព្រោះកើតមានសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ទាហាន លន់ នល់ បានប្រយុទ្ធជាមួយកងទ័ពរំដោះខ្មែរក្រហមកាន់តែខ្លាំងឡើងៗ រហូត







អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាម ក្នុងភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន និងភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចំនួន១០០នាក់ ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ដល់ឆ្នាំ១៩៧៣។ បន្ទាប់មក ឪពុកម្តាយខ្ញុំនាំកូនៗរត់ភៀសខ្លួនទៅភូមិមហាលាភ ដែលជាតំបន់រំដោះខ្មែរក្រហម។ មួយរយៈពេលក្រោយមក ឪពុកម្តាយខ្ញុំនាំកូនៗត្រឡប់មករស់នៅក្នុងភូមិវិញ។ នៅឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំត្រូវធ្វើការនៅកងប្រវាស់ដៃ និងប្រូតស្រូវយកមកចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង។ ខ្ញុំនៅចាំបានថា គ្រួសារខ្ញុំបានជិះស្រឡាង២ជាន់ជាមួយប្រជាជនជម្លៀសជាច្រើនផ្សេងទៀត។ គ្រួសាររបស់ខ្ញុំបានទៅដល់ភូមិឃ្លាំងស្បែក និងជិះរថយន្តបន្តរហូតដល់ស្ថានីយរទេះភ្លើង។ គ្រួសារខ្ញុំឡើងជិះរទេះភ្លើងរហូតទៅដល់ខេត្តបាត់ដំបង។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងចល័តដែលមានទិសដៅដក និងរែកសំណាបឲ្យអ្នកស្ទូងស្រូវ។ ប្អូនរបស់ខ្ញុំបានស្លាប់ដោយសារតែជំងឺ និងការអត់ឃ្លាន។ ខ្ញុំធ្វើការនៅការដ្ឋានបឹងពើតនៅខេត្តបាត់ដំបង។ បឹងនោះធំណាស់ ព្រោះខ្ញុំមើលដាច់កន្ទុយភ្នែក។ ខ្ញុំរួចផុតពីសេចក្តីស្លាប់ ប៉ុន្តែខ្ញុំបាត់បង់សមាជិកគ្រួសារជាច្រើននៅទីនោះ»។

**កើ ម៉ែសំ** អាយុ ៧០ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ចែករំលែកអំពីបទពិសោធន៍របស់ខ្លួនក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហមថា «ខ្ញុំឈ្មោះ កើ ម៉ែសំ កើតនៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំសប្បាយចិត្ត ដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាស្នាព្រះហស្តផ្ទាល់របស់ហ្លួងម៉ែ។ នៅពេលដែលខ្ញុំបើកមើលសៀវភៅនេះ ខ្ញុំនឹកឃើញពីបទពិសោធន៍ដែលធ្លាប់រស់នៅក្នុងព្រៃ និងត្រូវរត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយនាគ្រាដែលសង្គ្រាមផ្ទុះកាន់តែខ្លាំង នៅឆ្នាំ១៩៧៣។ មិនខុសពីអ្នកភូមិផ្សេងទៀត នៅឆ្នាំ១៩៧៦ ខ្ញុំ និងគ្រួសារ ត្រូវបានជម្លៀសទៅខេត្តបាត់ដំបង។ ខ្ញុំ និងគ្រួសារត្រូវបានដឹកតាមស្រឡាង ឡាន និងរទេះភ្លើងរហូតទៅដល់ទីនោះ។ ខ្ញុំនៅខេត្តបាត់ដំបងរហូតដល់ឆ្នាំ១៩៧៩។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» បានរំឭកខ្ញុំអំពីព្រឹត្តិការណ៍ទាំងពីរនេះ គឺការរត់ភៀសខ្លួនពីសង្គ្រាម និងការជម្លៀសចេញពីភូមិ»។

# ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មប្រគេន និងចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

## កំណាត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់ព្រះសង្ឃ អ្នកភូមិ និងសិស្សានុសិស្សនៅភូមិលាងលើ

ឡុង ដានី



នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ប្រគេន និងចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន ៦៧ ក្បាល ដល់ព្រះសង្ឃ តា យាយ អ៊ំ ពូ មីង និងសិស្សានុសិស្សនៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃពុធ ទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ប្រគេន និងចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៦៧ ក្បាល ដល់ព្រះសង្ឃ លោកតា លោកយាយ អ៊ំ ពូ មីង និងសិស្សានុសិស្ស នៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ជាកិច្ចចាប់ផ្តើមលោក ខាត់ រឿន អាជ្ញាធរភូមិលាជលើ ប្រកាសបើកកម្មវិធី និងបានសម្តែងការស្វាគមន៍ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម និងពុក ម៉ែ បងប្អូន ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងសិស្សានុសិស្ស។ លោក ខាត់ រឿន បានថ្លែងថា ប្អូនៗដែលជាយុវជនជំនាន់ក្រោយមិនធ្លាប់បានឆ្លងកាត់សម័យសង្គ្រាម និងសម័យខ្មែរក្រហមឡើយ។ ថ្ងៃនេះក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនឹងធ្វើការចែកសៀវភៅ «សាក្សី

ប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលនិយាយពីព្រះរាជដំណើររបស់ «ហ្វូងម៉ែ» យាងមកកាន់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៣ ជូនពុកម៉ែ បងប្អូន និងសិស្សានុសិស្ស។ សៀវភៅនេះគឺជាកំណត់ហេតុរបស់ «ហ្វូងម៉ែ» ផ្ទាល់។

កិច្ចបន្តលោក ឡុង ដានី សម្តែងការអរគុណដល់លោក ខាត់ រឿន ប្រធានភូមិលាជលើ ដែលបានជួយរៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩)។ លោក ឡុង ដានីបន្តថា ជាដំបូងខ្ញុំសូមធ្វើការណែនាំអំពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យរាជានុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ព ផ្សព្វផ្សាយ និងចែកជូនប្រជាជនខ្មែរនៅទូទាំងប្រទេស។ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុយាងពីទីក្រុងប៉េកាំងប្រទេសចិនមកទីក្រុងហាណូយ និងបន្តមកកាន់តំបន់រំដោះនៃប្រទេសកម្ពុជាមាតុភូមិជាទីស្នេហា ដែលព្រះអង្គបានឃ្លាតឆ្ងាយអស់រយៈពេលជាងបីឆ្នាំកន្លងមក។ ដើម្បីបានមកដល់មាតុភូមិ ព្រះអង្គត្រូវធ្វើដំណើរឆ្លងកាត់ផ្លូវលំហូជីមិញ។ បន្ទាប់មកព្រះអង្គបន្តដំណើរតាម «ផ្លូវលំ សីហនុ»។ ហ្វូងម៉ែបានបង្ហាញថា យើងគឺជាសមាជិកពិតប្រាកដនៃចលនាតស៊ូ ហើយយើងមិនញញើតញញើមក្នុងការប្រឈមមុខនឹងគ្រោះថ្នាក់ទាំងអស់ ដើម្បីវិលត្រឡប់មកកាន់មាតុភូមិ និងជួបសួរសុខទុក្ខជនរួមជាតិដែលតស៊ូយ៉ាងអង់អាចនៅក្នុងប្រទេស។ សៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បានបង្ហាញពីភាពទន់ភ្លន់ សេចក្តីថ្លៃថ្នូរ ជាពិសេសមានសារសំខាន់ដល់ប្រទេសជាតិ និងរំឭកអតីតកាលក្នុងឆ្នាំ១៩៧០។

បន្ទាប់ពីបានប្រគេន និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី



នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ប្រគេន និងចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន ៦៧ក្បាល ដល់ព្រះសង្ឃ តា យាយ អ៊ំ ពូមីង និងសិស្សានុសិស្សនៅភូមិលាជលើ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនព្រះសង្ឃ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្សរួចមក លោក ឡុង ដានី បន្ត កម្មវិធីវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង បានសង្ខេបពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយចាប់ផ្តើមពីគោលនយោបាយ៨ចំណុច ដែល ខ្មែរក្រហមបានអនុវត្តក្នុងអំឡុង៣ឆ្នាំ៨ខែ ២០ថ្ងៃ មានដូចខាងក្រោម៖

១) ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និង ទីប្រជុំជន

២) បំបាត់ផ្សារ និងរូបិយវត្ថុ

៣) កម្ទេចវត្តអារាម និងផ្សឹកព្រះសង្ឃ

៤) បិទសាលា និងគ្រឹះស្ថានសិក្សា

៥) បង្កើតសហករណ៍

៦) ផ្តាច់ទំនាក់ទំនង និងបំបែកបំបាក់ក្រុមគ្រួសារ

៧) សម្លាប់បញ្ញវន្តមន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់

៨) បណ្តេញជនជាតិវៀតណាម និងធ្វើសង្គ្រាម ជាមួយវៀតណាម

ខាងក្រោមគឺជាការចែករំលែករឿងរ៉ាវជីវិត របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ចំណាប់អារម្មណ៍របស់សិស្ស៖

ខ្ញុំបាទឈ្មោះ **ថុំ សារ៉េត** ភេទប្រុស អាយុ៩៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុង ភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមាន ឪពុកឈ្មោះ ឌិក និង ម្តាយឈ្មោះ ពុំ និងមានប្អូន ស្រីចំនួន២នាក់ ដែលបានស្លាប់នៅក្នុងសម័យខ្មែរ ក្រហមដោយសារគ្មានអាហារហូបគ្រប់គ្រាន់។ ខ្ញុំ មានប្រពន្ធឈ្មោះ គូ សាន អាយុ៨៩ឆ្នាំ និងមាន កូនចំនួន៨នាក់ ក្នុងនោះប្រុសចំនួន៤នាក់។ ខ្ញុំ ចូលធ្វើជាទាហានតាំងពីជំនាន់ស្សរនៅទល់ដែន ថៃជាមួយ ម៉ៅ ភារុន។ ខ្ញុំគឺជាប្រធានអង្គភាពដឹក នាំទាហានចំនួន១២០ ឡាននៅព្រំដែនប្រទេសថៃ ប៉ុន្តែពេលត្រឡប់មកវិញមានត្រឹម៨០ ឡានប៉ុណ្ណោះ។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ខ្ញុំមិនបានរស់នៅជួបជុំគ្រួសារ ព្រោះខ្ញុំត្រូវទៅឈរ ជើងនៅសមរភូមិ។ នៅអំឡុងឆ្នាំ១៩៩០ ខ្ញុំបានត្រឡប់ មកស្រុកកំណើត បន្ទាប់មកធ្វើជាមេឃុំជាំ ហើយ បច្ចុប្បន្នខ្ញុំចូលនិវត្តន៍ហើយ។

ខ្ញុំឈ្មោះ **មុំ រីម** ភេទស្រី អាយុ៦៦ឆ្នាំ មាន ទីកន្លែងកំណើតនៅក្នុងភូមិលាជលើ ឃុំជាំ ស្រុក មេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិ លាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមាន ឪពុកឈ្មោះ មុំ សៅ និងម្តាយឈ្មោះ ឃុំ ប្រាញ់។ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺអស់ហើយ។

នៅឆ្នាំ១៩៧០ អាមេរិកាំងទម្លាក់គ្រាប់បែក នៅតាមជាយភូមិធ្វើឲ្យឆេះផ្ទះប្រជាជនអស់ ហើយ គ្រួសាររបស់ខ្ញុំរត់ទៅនៅខាងស្រែស្រណុក ខេត្ត ក្រចេះ។ គ្រួសារខ្ញុំបានបន្តរស់នៅស្រែស្រណុក និង ស៊ីឈ្នួលគេនៅទីនោះបានប្រហែល៦ខែ ទើបត្រឡប់ មកភូមិវិញ។ ខ្ញុំស្នាក់នៅតាមគុម្ពចេករយៈពេល២ ឆ្នាំ ទើបសង់ផ្ទះដោយដំបូលប្រក់ស្លឹក និងជញ្ជាំង បាំងតង់។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមបង្កើតជា សហករណ៍ហូបបាយរួម ហើយការរស់នៅចាប់ផ្តើម លំបាក និងមិនបានជួបជុំគ្រួសារឡើយ។ ខ្មែរក្រហម បានចាត់តាំងខ្ញុំឲ្យទៅរស់នៅតាមកងចល័ត។ ខ្ញុំធ្វើ ការដោយមិនបានសម្រាក និងមិនបានងូតទឹកឡើយ។ ខ្ញុំមិនបានងូតទឹករយៈពេល៥ខែ ហើយសូម្បីរដូវក៏ គ្មានដែរ។ ខ្មែរក្រហមប្រើខ្ញុំឲ្យលើកទំនប់នៅភូមិ ពញាំ ឃុំជាំ បន្ទាប់មកទៅលើកទំនប់នៅបឹងក្រចាប់ ដោយខ្ញុំដើរមួយយប់មួយថ្ងៃទើបទៅដល់បឹងនោះ។ ម្តាយខ្ញុំបានផ្តាំផ្ញើខ្ញុំថាប្រយ័ត្នមានគ្រោះថ្នាក់ ហើយ ខ្ញុំក៏បានឆ្លើយតបទៅគាត់វិញថា «ម៉ែមិនបាច់បារម្ភ ពីខ្ញុំទេ បើស្លាប់ក៏ស្លាប់ដើម្បីជាតិដែរ» ហើយទោះ បីខ្ញុំមិនបានហូបឆ្អែតក៏ខ្ញុំមិនដែលរអ៊ូដែរ។ ពេល ត្រឡប់មកពីបឹងក្រចាប់វិញ ខ្ញុំបានយកបាយទៅឲ្យ កងកម្លាំងនៅសមរភូមិមុខ និងសែងអ្នករបួសមក ព្យាបាល។ ក្រោយមក ខ្ញុំបានទៅរស់នៅអាលួច ស្ថិត នៅក្នុងស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំត្រូវងើបដឹកប្រឡាយ តាំងពីម៉ោង៣ទៀបភ្លឺ។ ខ្ញុំរស់នៅទីនោះបានរយៈ







ពេល៥ទៅ៦ខែ ក៏ផ្លាស់ទៅរស់នៅស្រុកស្ទឹងត្រង់ និងស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្ញុំត្រូវបានខ្មែរក្រហមចាប់ខ្លួនដោយចោទថាជាគិញសម្ងាត់របស់ភូមិភាគបូព៌ា ប៉ុន្តែប្រជាជននៅទីនោះជួយបញ្ជាក់ ទើបខ្មែរក្រហមដោះលែងខ្ញុំឲ្យត្រឡប់មកផ្ទះវិញ។

ខ្ញុំឈ្មោះ **ស្រេង សំណាង** គឺជាសិស្ស សូមអរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មដែលបានរៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដើម្បីផ្តល់ឱកាសឲ្យខ្ញុំ ក៏ដូចជាសិស្សានុសិស្សផ្សេងទៀត បានចូលរួមសិក្សាស្រាវជ្រាវ និងយល់ដឹងអំពីប្រវត្តិ-សាស្ត្រ និងបានស្តាប់រឿងរ៉ាវរបស់លោកតា លោកយាយ ដែលធ្លាប់បានជួបប្រទះនៅក្នុងសម័យសង្គ្រាម និងសម័យខ្មែរក្រហម។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ប្រគេន និងចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន ៦៧ក្បាល ដល់ព្រះសង្ឃ តា យាយ អ៊ំ ពូមីង និងសិស្សានុសិស្សនៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សាស្ត្រាចារ្យ និស្សិត សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំទទួលសៀវភៅ

## «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ឈុំ រ៉ា



នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និង និស្សិត នៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ សរុបចំនួន១៨០នាក់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង១០ព្រឹក ថ្ងៃសុក្រ ទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូន សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និង និស្សិត នៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ចំនួន១៨០នាក់។

ជាកិច្ចចាប់ផ្ដើម លោកស្រី តុង បូណា គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ តំណាងឯកឧត្តម ពិន វណ្ណារ៉ូ សាកលវិទ្យាធិការសាកលវិទ្យាល័យ ហេង សំរិនត្បូងឃ្មុំបានស្វាគមន៍ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម លោកគ្រូ អ្នកគ្រូទាំងអស់ និងនិស្សិត មានវត្តមានក្នុងថ្ងៃនេះ។ លោកស្រី តុង បូណា លើកឡើងថា ខ្ញុំពិតជាមានសេចក្ដីរីករាយក្រៃលែងដែលក្រុមការងារ

មជ្ឈមណ្ឌលឯកសារកោះថ្មបាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាសៀវភៅកំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងតម្កល់នៅបណ្ណាល័យ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះមានខ្លឹមសារសំខាន់ មានប្រយោជន៍ដល់អ្នកសិក្សាប្រវត្តិសាស្ត្រ អ្នកសិក្សាស្រាវជ្រាវ រួមទាំងប្រជាជនខ្មែរទាំងអស់បានយល់ដឹងអំពីប្រវត្តិសាស្ត្រកាន់តែច្បាស់ជាងមុនៗ សំខាន់បំផុតជាស្នាព្រះហស្ត ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលទ្រង់បានសរសេរអំឡុងពេលយាងចូលប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ៗ ក្នុងឱកាសនោះលោកស្រី គុង បូណា បានលើកពីមុខជំនាញនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្ស-សាស្ត្រនៃសាកលវិទ្យាល័យ ហេង សំរិនត្បូងឃ្មុំ គឺមានជំនាញចំនួន៥៖ ១) ប្រវត្តិសាស្ត្រ ២) ទស្សន-វិជ្ជា ៣) រដ្ឋបាលសាធារណៈ ៤) នីតិសាស្ត្រ និង ៥) អក្សរសាស្ត្រខ្មែរៗ

បន្ទាប់មក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានណែនាំខ្លួន និងបង្ហាញអំពីគោលបំណងការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្មនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការពារជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជាៗ ការបើកដំណើការមជ្ឈមណ្ឌលឯកសារកោះថ្មមានគោលបំណងដូចខាងក្រោម៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ដល់ឆ្នាំ១៩៩០ៗ

២) ពង្រឹងការកសាងសន្តិភាព និងទប់ស្កាត់ជម្លោះតាមរយៈកម្មវិធីអប់រំជាឱកាសសម្រាប់យុវជនរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងការចូលរួមៗ

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែក និងបង្រៀនក្មេងៗនូវបទពិសោធន៍របស់ពួកគាត់ធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមៗ

៤) ប្រមែប្រមូលចងក្រងរឿងរ៉ាវ និងបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយរបបនោះៗ

៥) ជួយសម្របសម្រួលលើកម្រោងការលើកកម្ពស់សិទ្ធិនិងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៃមជ្ឈមណ្ឌលឯកសារកម្ពុជាៗ មជ្ឈមណ្ឌលឯកសារកោះថ្ម ក៏មានពិព័រណ៍រូបថត រូបគំនូរ ដោយចាប់ផ្តើមពីបណ្តុំរូបថតនៃសង្គ្រាមនៅទសវត្សរ៍ឆ្នាំ១៩៦០ នៅតំបន់កោះថ្ម, បណ្តុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បណ្តុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, បណ្តុំរូបថតកស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បណ្តុំរូបគំនូរដែលសមមិត្ត ហ៊ុន សែន (សម្តេច



នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និង និស្សិត នៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ សរុបចំនួន១៨០នាក់ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តេជោ ហ៊ុន សែន) និងយុទ្ធមិត្ត៤រូបចាកចេញទៅប្រទេសវៀតណាមដើម្បីរៀបចំកម្លាំងវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងផែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូបបានចាកចេញពីបន្ទាយយោធានៅភូមិកោះថ្មទៅតំបន់ព្រំដែនអាងដាច់ដើមត្រយឹង (X-16) និងទីតាំងមួយចំនួននៅក្នុងស្រុកឡុកនិញ ខេត្តសុងបែរ ប្រទេសវៀតណាម។

ឆ្លៀតឱកាសនោះ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ធ្វើការណែនាំសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរបានបង្ហាញអំពីព្រះរាជហឫទ័យ សង្កេតផ្ទាល់របស់សម្ដេចព្រះមហាក្សត្រី ក្នុងព្រះរាជបេសកកម្ម និងព្រះរាជដំណើររបស់ព្រះអង្គយាងទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ស្ថិតនៅក្នុងប្រទេសកម្ពុជា។ សម្ដេចព្រះមហាក្សត្រីបានយាងអមព្រះរាជដំណើរព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ចាប់ផ្ដើមចេញពីការយាងព្រះរាជដំណើរតាមព្រះទីនាំងយន្តហោះចេញពីទីក្រុងប៉េកាំង ឆ្ពោះទៅកាន់ទីក្រុងហាណូយ និងបន្ទាប់មកបន្តដំណើរដោយព្រះទីនាំងរថយន្តតាមបណ្ដោយផ្លូវលំ ហូជីមិញ ឆ្ពោះទៅកាន់ខេត្តសៀមរាប (អង្គរវត្ត) ដោយឆ្លងកាត់ផ្នែកខ្លះនៃផ្លូវលំ សីហនុ ក្នុងរយៈពេលប្រមាណ៣៩ថ្ងៃ។ «ហ្លួងម៉ែ» ទ្រង់សព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតដល់មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ ព្រះវររាជមាតាជាតិខ្មែរ ជាលើកទីមួយ សម្រាប់ចែក ប្រគេន និងជូនប្រជាជនខ្មែរ ហើយផ្សព្វផ្សាយដល់សាធារណជនទូទាំងប្រទេស។



នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និង និស្សិត នៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ សរុបចំនួន១៨០នាក់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សានុសិស្សវិទ្យាល័យ ក្រាំងស្លា អាន អំពី ព្រឹត្តិការណ៍នៃការយាងមកដល់ប្រទេសកម្ពុជា

## របស់សម្តេចព្រះនរោត្តម សីហនុ និងព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ នៅខែមីនា ឆ្នាំ១៩៧៣

*រីម ស្រីស្រស់*



*សិស្សានុសិស្សវិទ្យាល័យ ក្រាំងស្លា ស្រុកព្រៃកប្បាស ខេត្តតាកែវ អានអំពីព្រឹត្តិការណ៍នៃការយាងមកដល់ប្រទេសកម្ពុជារបស់សម្តេចព្រះនរោត្តម សីហនុ និងព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ នៅខែមីនា ឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស៊ិន ស្រីពេជ្រ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ក្រាំងស្លា ស្រុកព្រៃកប្បាស ខេត្តតាកែវ បានអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចប់មុនគេក្នុងចំណោមមិត្តរួមថ្នាក់ទាំងអស់ ដែលចូលរួមនៅក្នុងកម្មវិធីចែកសៀវភៅ នាព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នៅក្នុងបរិវេណវិទ្យាល័យ ក្រាំងស្លា។ ស្រីពេជ្រ ត្រូវបានណែនាំឲ្យអាននៅផ្នែកទី២ នៃដំណើរយាងមកកាន់ប្រទេសកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ដោយចាប់ផ្តើមអានពីទំព័រទី៣៤ និងបញ្ចប់នៅ ទំព័រទី៣៩។ នេះគឺជាកំណត់ហេតុថ្ងៃទី៩ នៃការយាងមកកាន់ប្រទេសកម្ពុជា និងជាថ្ងៃទី១ នៃការយាងមកដល់មាតុប្រទេសរបស់ព្រះអង្គទាំងទ្វេ។ សំណេរនៅក្នុងកំណត់ហេតុថ្ងៃទី៩នេះ បានរៀបរាប់អំពី សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ បានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពី ហ៊ូ នឹម គឺជា



សិស្សានុសិស្សវិទ្យាល័យ ក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ អានអំពីព្រឹត្តិការណ៍នៃការយាងមកដល់ប្រទេសកម្ពុជារបស់សម្តេចព្រះនរោត្តម សីហនុ និងព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ នៅខែមីនា ឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រដ្ឋមន្ត្រីក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និង សុន សេន គឺជាប្រធានអគ្គសេនាធិការនៃកងទ័ពរំដោះ។

**ទួន ច័ន្ទនិត្យ** គឺជាសិស្សថ្នាក់ទី១២ ម្នាក់ទៀត បានអានបន្តពី ស្រីពេជ្រ ចាប់ពីទំព័រទី៤១ ដល់ទំព័រ៤៤។ ទំព័រនេះ បង្ហាញអំពីដំណើរជាប្រវត្តិ-សាស្ត្រក្នុងថ្ងៃទី២ ដល់ ទី៤ របស់សម្តេចទាំងទ្វេនៅក្នុងទឹកដីប្រទេសកម្ពុជា ជាថ្ងៃដែលព្រះអង្គត្រូវបានទទួលស្វាគមន៍ដោយ ខៀវ សំផន និង សាឡុត ស នៅក្នុងព្រៃ។ នៅក្នុងសេចក្តីកំណត់ហេតុ សម្តេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ បានរៀបរាប់អំពីការបន្តទម្លាក់គ្រាប់បែកពីលើអាកាសដោយពួកសត្រូវ មកលើទីតាំងមួយចំនួននៃទឹកដីប្រទេសកម្ពុជា។

**សន សុគន្ធា** បានអានបន្តពី ច័ន្ទទិត្យ ពីទំព័រទី៤៧ដល់ទំព័រទី៥២។ ទំព័រនេះ រៀបរាប់ពីការព្រួយបារម្ភចំពោះយន្តហោះសត្រូវ ដែលតែងតែហោះហើរចុះឡើងនៅពីលើអាកាសក្បែរព្រះរាជសំណាក់បណ្តោះអាសន្នរបស់ព្រះអង្គ។ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ទ្រង់បានឈ្វេងយល់ថា យន្តហោះសត្រូវទាំងនោះពិតជាបានដឹងពីព្រះរាជដំណើរយាងមកប្រទេសកម្ពុជារបស់ព្រះអង្គហើយ ទើបបានជាហោះពីលើអាកាសមិនដាច់សោះ។ សមាជិកកម្មាភិបាលខ្មែរក្រហមបានទូលសម្តេចថា ទីកន្លែងដែលសម្តេចកំពុងស្នាក់នៅនេះ គឺពុំដែលមានយន្តហោះហោះកាត់ទេ។ ប៉ុន្តែពេលនេះ ហាក់ដូចជាចម្លែកណាស់។ ទីបំផុត សម្តេចទាំងទ្វេ ត្រូវបានចាកចេញពីទីកន្លែងនេះឆ្ពោះទៅកាន់តំបន់ផ្សេងទៀតដោយសុវត្ថិភាព។

**ភឹម សុភី** បានអានបន្តពី សុគន្ធា ត្រង់ទំព័រទី៥៣ ហើយបានបញ្ចប់ការអាននៅត្រឹម ទំព័រទី៥៦។ ទំព័រដែល សុភីបានអានបង្ហាញពីដំណើររបស់សម្តេចព្រះ នរោត្តម សីហនុ និងព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ យាងមកដល់ទឹកដីខេត្តព្រះវិហារ និងបានបន្តទៅកាន់ខេត្តសៀមរាប។ ក្នុងដំណើរដ៏វែងឆ្ងាយនេះ ព្រះអង្គទាំងទ្វេជួបប្រទះការលំបាកជាច្រើន ដោយសារការគេចចេញពីការទម្លាក់គ្រាប់បែកពីកម្លាំងសត្រូវ។ នៅតាមផ្លូវ



សិស្សានុសិស្សវិទ្យាល័យ ក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ អានអំពីព្រឹត្តិការណ៍នៃការយាងមកដល់ប្រទេសកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ និងព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ នៅខែមីនា ឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះអង្គត្រូវបានទទួលស្វាគមន៍ពី ហ៊ូ យន់ និង ទួន ជា។ បន្ទាប់ពីអានចប់សិស្សានុសិស្សទាំងអស់ដល់ម៉ោងសម្រាកដោយបាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដើម្បីទុកអាននៅផ្ទះបន្តទៀត។

សូមរំឭកថា វេទិកាអំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នេះបានធ្វើឡើងនៅក្នុងកម្មវិធីចែកសៀវភៅមួយ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៅក្នុងបរិវេណវិទ្យាល័យ ក្រាំងស្វា កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានសិស្សានុសិស្សចំនួន១១៥នាក់ ក្នុងនោះស្រី៤០នាក់ បានចូលរួមនៅក្នុងកម្មវិធីនេះ ហើយសៀវភៅចំនួន១១៥ក្បាល ក៏ត្រូវបានចែកជូនដល់សិស្សានុសិស្សទាំងនោះដែរ។ កម្មវិធីនេះ មានការចូលរួមពីនាយក នាយករង និងគ្រូបង្រៀននៃវិទ្យាល័យ ក្រាំងស្វា ហើយបានបញ្ចប់នៅម៉ោង១១ព្រឹក។

បន្ទាប់ពីបានទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សិស្សបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **ម៉ិល សុខា** ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យក្រាំងស្វា។ ខ្ញុំមានអារម្មណ៍រីករាយ ដែលបានអានសៀវភៅដែលសរសេរចងក្រងដោយសម្តេចយាយជាលើកដំបូង។ ខ្ញុំចង់ដឹងបន្ថែមទៀតពីប្រវត្តិសាស្ត្រខ្មែរ។ ខ្ញុំបានដឹងអំពីការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ព្រោះព្រះអង្គចង់បង្រួបបង្រួមជាតិឡើងវិញ។ ជាចុងក្រោយខ្ញុំសូមថ្វាយព្រះពរដល់សម្តេចយាយឲ្យមានព្រះជន្មរាប់រយព្រះវស្សា នៅគង់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅជំនាន់ក្រោយ។

ខ្ញុំឈ្មោះ **រណា ស្រីពេជ** ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យក្រាំងស្វា។ ខ្ញុំមានអារម្មណ៍រំភើបដែលទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលទើបបោះពុម្ព។ សៀវភៅនេះបានបង្ហាញឲ្យឃើញច្បាស់ពីការយាងត្រឡប់មកវិញរបស់សម្តេចយាយ និងសម្តេចតាមកកាន់ប្រទេសកម្ពុជា បន្ទាប់ពីបានចាកចេញពីប្រទេសកម្ពុជារយៈពេលជាង៣ឆ្នាំ។ ខ្ញុំចង់ឲ្យសិស្សានុសិស្សទាំងអស់យល់ដឹងពីប្រវត្តិ-សាស្ត្រឲ្យបានច្រើនជាពិសេសអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះឲ្យបានចប់។ ខ្ញុំបានដឹងអំពីការធ្វើរដ្ឋប្រហាររបស់ លន់ នល់ និងមានការទម្លាក់គ្រាប់បែកជាច្រើនដែលធ្វើឲ្យបាត់បង់ជីវិតមនុស្ស។ បន្ទាប់មក សម្តេចព្រះ នរោត្តម សីហនុ បានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីរំដោះកម្ពុជាចេញពីរបប លន់ នល់។ ជាចុងក្រោយ ខ្ញុំសូមថ្វាយព្រះពរឲ្យសម្តេចយាយមានព្រះជន្មាយុជាងរយព្រះវស្សា ដើម្បីជាម្លប់ដល់កូនចៅជំនាន់ក្រោយ។

# គុយ ដុង ៖ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាគ្រូរបស់ខ្ញុំ

ផេង ពង្សរ៉ាស៊ី



ពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០០នាក់ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ របស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ពីថ្ងៃទី១៥ ដល់ ១៧ ខែកញ្ញា ឆ្នាំ២០២៣ អ្នកចូលរួមជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងចន្លោះពីឆ្នាំ១៩៧០ ដល់ ឆ្នាំ ១៩៧៩។ ចំណាប់អារម្មណ៍ទាំងអស់ បង្ហាញពីអារម្មណ៍ផ្ទាល់ខ្លួននៅពេលទទួលបានសៀវភៅ ការរំឭកឡើងវិញពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម និងការឈឺចាប់បន្ថែមពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រក្នុងឆ្នាំ១៩៧៣។

លោក គុយ ដុង អាយុ៧៥ឆ្នាំ រស់នៅឃុំក្តាញ់ បាននិយាយថា គាត់សប្បាយចិត្តនៅពេលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ព្រោះសៀវភៅនេះបានបកស្រាយចម្ងល់ ដែលគាត់បានឆ្ងល់ជាយូរមកហើយ ពីវត្តមានរបស់សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ នៅមុនឆ្នាំ១៩៧៥។ មិនតែប៉ុណ្ណោះ គាត់ក៏សប្បាយចិត្ត ព្រោះអាចជួយដោះស្រាយចម្ងល់ដល់ក្មេងៗនៅក្នុងភូមិ ដែលតែងតែសួរនាំគាត់ពីកន្លែងដែលសម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ស្នាក់នៅមុនឆ្នាំ១៩៧៥។ គុយ ដុង គឺជាអតីតនាយកសាលាបឋមសិក្សាមួយកន្លែងនៅក្នុងឃុំក្តាញ់ ហើយលោកបានចូលនិវត្តន៍

អស់រយៈពេលជិត១០ឆ្នាំកន្លងមកហើយ។

ជាមួយនឹងទឹកមុខញញឹម លោក គុយ ដុង បានលើកឡើងដូច្នេះថា «ខ្ញុំសូមអរគុណជាអតិបរមាចំពោះការពាំនាំយកឯកសារសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» មកចែកជូនប្រជាជននៅទីនេះ។ ខ្ញុំធ្លាប់ជួបប្រទះនូវការសាកសួរពីក្មេងៗ និងចាស់ៗមួយចំនួនថា តើនៅក្នុងចន្លោះឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៥ សម្តេចតា សម្តេចយាយ នៅឯណា? ខ្ញុំរកអ៊ីឆ្លើយប្រាប់ទៅក្មេងៗវិញមិនបានទេ ព្រោះខ្ញុំមិនដឹង។ ខ្ញុំគ្រាន់តែដឹងតគ្នាថា សម្តេចតាគឺជាអ្នកតស៊ូដើម្បីប្រទេសជាតិនៅក្រោយរដ្ឋប្រហារ។ ឯកសារនេះ បានបង្ហាញច្បាស់តែម្តង។ សៀវភៅនេះ គឺជាគ្រូរបស់ខ្ញុំ។ ខ្ញុំសូមអរគុណណាស់ ព្រោះក្មេងៗ និងតាយាយខ្លះអត់បានដឹងទេ។ កាលពីខ្ញុំនៅក្មេងៗ ខ្ញុំក៏ជាអ្នករៀនសូត្រម្នាក់ដែរ ប៉ុន្តែខ្ញុំនៅខ្វះចន្លោះកន្លែងនេះ។ ដល់ពេលបានអានសៀវភៅនេះ ខ្ញុំដឹងច្បាស់តែម្តង។ ខ្ញុំទទួលបានចម្លើយច្បាស់ហើយថា សម្តេចតា សម្តេចយាយ ទោះបីជាលោកទាំងពីរនៅឆ្ងាយមែន តែលោកខំប្រឹងប្រែងណាស់ដើម្បីកូនចៅ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ បែរជាលេចអគ្គលេខាបក្ស ប៉ុល ពត ជាអ្នកគ្រប់គ្រងប្រទេសទៅវិញ ហើយនៅក្នុងសៀវភៅនេះ ក៏បានបង្ហាញថា ប៉ុល ពត មានគម្រោងក្បត់តាំងពីឆ្នាំ១៩៧៣មក។ ខ្ញុំអរគុណណាស់ ថ្ងៃក្រោយ ខ្ញុំមានសំអាងហើយ ប្រសិនមានក្មេងៗសួរទៀត ខ្ញុំបង្ហាញសៀវភៅនេះ ហើយខ្ញុំអាចរៀបរាប់ប្រាប់ក្មេងៗបាន ដោយសំអាងទៅលើកំណត់ត្រាសម្តេចយាយ»។

សូមរំឭកថា កម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ក្នុងរយៈពេលបីថ្ងៃនេះ មានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០០នាក់ ក្នុងនោះស្រី១៨៧នាក់ មកពីឃុំក្តាញ់ ឃុំកំពង់រាប និងឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ អ្នកចូលរួមទាំងអស់ ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ម្នាក់មួយក្បាល។ កម្មវិធីនេះប្រព្រឹត្តទៅបាន ដោយមានការចូលរួមសហការពីអាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក ឃុំ និងភូមិ ព្រមទាំងបានដំណើរការតាមកម្មវិធីដែលបានគ្រោងទុក គឺ ១) មតិស្វាគមន៍ និងផ្តាំផ្ញើរបស់មេឃុំមេភូមិ ២) បទបង្ហាញខ្លីស្តីពីប្រវត្តិសាស្ត្រមុន និងក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ៣) អំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» របស់អ្នកចូលរួម និង ៤) វេទិកាពិភាក្សាពីមាតិកាប្រវត្តិសាស្ត្រ និងសេចក្តីថ្លែងអំណរគុណរបស់អ្នកចូលរួម។ ការចែកចាយសៀវភៅនេះ គឺក្នុងគោលបំណងថែរក្សាប្រវត្តិសាស្ត្រ ការចងចាំពីប្រវត្តិសាស្ត្រ និងការទប់ស្កាត់ការវិលត្រឡប់មកវិញនៃប្រវត្តិសាស្ត្រប្រល័យពូជសាសន៍ ប៉ុល ពត។







ពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០០នាក់ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ

## របស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តត្បូងឃ្មុំ និងក្រចេះ

ឡុង ដានី



ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន ៣០០ក្បាល ទៅចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្មីៗនេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៣០០ក្បាល ទៅចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តចំនួនពីរ គឺខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ។

នៅថ្ងៃទី១៤ និងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាលជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ដារ នៃស្រុកមេមត់ វិទ្យាល័យក្រែកនៃស្រុកពញាក្រែក និងវិទ្យាល័យ ហ៊ុន សែនខ្នារ នៃស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

បន្ទាប់មក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចែក



ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន ៣០០ក្បាល ទៅចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១៥០ក្បាល ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅវិទ្យាល័យ ហ៊ុនសែន ស្ទួល នៃស្រុកស្ទួល ខេត្តក្រចេះ។

តមក នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៥០ក្បាល ទៀត ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់នៃស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

មុនពេលចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានមានប្រសាសន៍ថា សៀវភៅកំណត់ហេតុនេះ គឺជាព្រះរាជសំណេរដើម និងមិនបានកែសម្រួលដោយឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព និងសេចក្តីថ្លៃថ្នូរ ក្នុងអំឡុងពេលដែលព្រះអង្គអមព្រះរាជដំណើរសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងតាមយន្តហោះចេញពីទីក្រុងប៉េកាំងទៅកាន់ទីក្រុងហាណូយ និងទីក្រុងដុងហូយ ខេត្តក័ងប៊ិញនៃប្រទេសវៀតណាម និងយាងបន្តដោយរថយន្តតាមបណ្តោយផ្លូវលំហូជីមិញទៅកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅក្នុងឆ្នាំ១៩៧៣។ ព្រះរាជដំណើររបស់ទ្រង់ទាំងពីរអង្គត្រូវចំណាយពេលជាងមួយខែ ដោយបានបង្ហាញអំពីសេចក្តីថ្លៃថ្នូរ និងភាពទន់ភ្លន់របស់ព្រះមហាក្សត្រី ទោះជាព្រះរាជដំណើររបស់ព្រះអង្គស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍នាពេលនោះក្តី។




*ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន ៣០០ក្បាល ទៅចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ព្រះមហាក្សត្រគឺជាសាក្សីផ្ទាល់ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងរយៈកាលជាង៧ទសវត្សរ៍កន្លងមក ហើយព្រះអង្គគឺជាឥស្សរជនប្រវត្តិសាស្ត្រដ៏លេចធ្លោមួយព្រះអង្គក្នុងអំឡុងពេលនោះ។ ព្រះរាជសំណេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ទ្រង់ ផ្តល់នូវព្រះរាជតម្រិះសង្ខេបអំពីជំពូកដ៏សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។*

*ក្រោយពីទទួលបានសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សិស្សា-នុសិស្សលើកឡើងនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម ៖*

**ខន្ធ ស្សុតធីលីយ៉ា** *ភេទស្រី អាយុ១៦ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ស្ទួល រៀបរាប់ថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» និយាយអំពីដំណើររបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ក្នុងអំឡុងឆ្នាំ១៩៧៣ យាងចូលមកប្រទេសកម្ពុជា។ ជាពិសេសនៅក្នុងសៀវភៅនេះបានបង្ហាញពីសម័យសង្គ្រាមកាលពីឆ្នាំ១៩៧០ដែរ។ ខ្ញុំពិតជាចាប់អារម្មណ៍ទៅលើសៀវភៅនេះ ហើយជាលើកទីមួយដែលខ្ញុំបានទទួលវា។ ខ្ញុំអរគុណយ៉ាងខ្លាំងដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានចែកសៀវភៅដល់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្ស វិទ្យាល័យស្ទួល។*

**អ៊ឹម ឈាង** *ភេទប្រុស អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុនសែន ស្ទួល និយាយថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាស្នាព្រះហស្តរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ បានកត់ត្រាអំពីកំណត់ហេតុរបស់ទ្រង់ និងរៀបរាប់គ្រប់កន្លែងដែលទ្រង់បានឆ្លងកាត់។ សៀវភៅនេះបានរៀបរាប់អំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាមានដែនទី និងរូបភាពដែលឆ្លុះបញ្ចាំងពីតថភាពនៅក្នុងប្រទេសកម្ពុជានាសម័យកាលនោះ។ ខ្ញុំពិតជាសប្បាយចិត្តយ៉ាងខ្លាំងដែលទទួលបានសៀវភៅនេះ ព្រោះវាមានសារសំខាន់សម្រាប់ខ្ញុំជាសិស្សថ្នាក់ទី១២។ ចុងក្រោយ ខ្ញុំសូមអរគុណដល់លោកគ្រូអ្នកគ្រូ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានអញ្ជើញមកដល់សាលាខ្ញុំផ្ទាល់ ព្រមទាំងចែកសៀវភៅដល់លោកគ្រូ អ្នកគ្រូ និងសិស្សថ្នាក់ទី១២រួមទាំងខ្ញុំ។*

**ហៀត អាស៊ីរ៉ា** *ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សទី១២នៃវិទ្យាល័យ ហ៊ុន សែន ស្ទួល ឲ្យដឹងថា ខ្ញុំមានឪពុកឈ្មោះ សាម៉ា ហៀត អាយុ៤២ឆ្នាំ មានមុខរបរជាអ្នកលក់ដូរ ចំណែកម្តាយខ្ញុំឈ្មោះ សារីហា សានី អាយុ៣៧ឆ្នាំ មុខរបរជាអ្នកលក់ដូរដែរ។ នៅព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ វាគឺជាលើកទីមួយដែលខ្ញុំទទួលបានសៀវភៅនេះ ដែលរៀបរាប់អំពីព្រះរាជដំណើរជីវិតរបស់ហ្លួងម៉ែ។ ខ្ញុំពិតជាត្រេកអរយ៉ាងខ្លាំងដែលទទួលបានសៀវភៅនេះ ហើយសៀវភៅនេះល្អណាស់សម្រាប់ខ្ញុំដែលជាសិស្សទី១២ និងជាក្មេងជំនាន់ក្រោយសម្រាប់សិក្សាឈ្វេងយល់ពីប្រវត្តិ*

សាស្ត្ររបស់ប្រទេសជាតិខ្លួន។ ខ្ញុំអរគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្មដែលបានចែកសៀវភៅនេះដោយឥតគិតថ្លៃ។

**អ៊ាន ម៉ាលីន** ភេទស្រី អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ និយាយថា សៀវភៅ «សាកវ្យប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បង្ហាញអំពីដំណើរយាងចូលប្រទេសកម្ពុជាជាលើកដំបូងរបស់ទ្រង់ នៅឆ្នាំ១៩៧៣។ សៀវភៅនេះមានសារសំខាន់ជាពិសេសសម្រាប់ខ្ញុំគឺជាសិស្សយកទៅសិក្សារៀនសូត្របន្ថែមដើម្បីទទួលបានចំណេះដឹងទូលំទូលាយ។ ខ្ញុំបានដឹងអំពីការយាងរបស់ទ្រង់មកជួបជាមួយប្រជានុរាស្ត្រកម្ពុជា និងការយាងត្រឡប់ទៅកាន់ប្រទេសចិនវិញ។ ខ្ញុំសំណូមពរដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មឲ្យចែកសៀវភៅ «សាកវ្យប្រវត្តិសាស្ត្រ» នេះជូនប្រជាជននៅក្នុងប្រទេសកម្ពុជាបានអានទាំងអស់គ្នា។ ខ្ញុំនឹងអានសៀវភៅដ៏ល្អនេះឲ្យចប់ដើម្បីទទួលបានចំណេះដឹងថ្មីៗ។

**ទី សុខគា** ភេទប្រុស អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ រៀបរាប់ថា ថ្ងៃនេះខ្ញុំពិតជាត្រេកអរ និងសប្បាយចិត្តណាស់ដែលទទួលបានសៀវភៅដែលនិយាយអំពីដំណើររបស់សម្ដេចម៉ែយាងត្រឡប់ចូលមកប្រទេសកម្ពុជា និងយាងត្រឡប់ទៅប្រទេសចិន។ នៅក្នុងសៀវភៅនេះ បង្ហាញអំពីមេដឹកនាំសំខាន់ៗ ដែនទីទេសភាពនៅក្នុងព្រៃ។ ខ្ញុំចង់បានសៀវភៅ «សាកវ្យប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនទៅឪពុករបស់ខ្ញុំចំនួនមួយក្បាល ព្រោះឪពុករបស់ខ្ញុំចូលចិត្តអានសៀវភៅអំពីព្រះមហាក្សត្រ និងប្រវត្តិសាស្ត្រខ្មែរ។ ចុងក្រោយ ខ្ញុំសូមអរគុណដល់លោកគ្រូ អ្នកគ្រូ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម និងសូមជូនពរឲ្យមានសុខភាពល្អ។









ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បាននាំយកសៀវភៅ «សាកវ្យប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៣០០ក្បាល ទៅចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសាកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ

## របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ-អ្នកគ្រូ និងសិស្ស នៅវិទ្យាល័យពាមជាំង

**ទី ស៊ីថា**




នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សចំនួន ១៩០នាក់ ក្នុងនោះមានស្រី១០០នាក់ នៅវិទ្យាល័យពាមជាំង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*នៅវេលាម៉ោង៩:៣០នាទីព្រឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើដំណើរទៅដល់វិទ្យាល័យពាមជាំង ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងធ្វើការវាយតម្លៃចំពោះសិស្សានុសិស្សដែលធ្លាប់បានមកទស្សកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ (១៩៧៥ -១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។*

*ជាកិច្ចចាប់ផ្តើមលោក ហែម ធារី នាយកវិទ្យាល័យពាមជាំងបានថ្លែងបើកកម្មវិធី និងស្វាគមន៍លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ព្រមទាំងក្រុមការងារទាំងអស់ដែលបានអញ្ជើញមកវិទ្យាល័យពាមជាំង ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី*



នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សចំនួន ១៩០នាក់ ក្នុងនោះមានស្រី១០០នាក់ នៅវិទ្យាល័យពាមជាំង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សចំនួន១៩០នាក់ ក្នុងនោះមានស្រី១០០នាក់។ លោក ហែម ធារី បានបន្តថា ខ្ញុំបាទតំណាងឲ្យលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ទាំងអស់ សូមថ្លែងអំណរគុណដល់ហ្លួងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានអនុញ្ញាតឲ្យក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មកចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅវិទ្យាល័យពាមជាំងនៅថ្ងៃនេះ។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានអរគុណដល់លោកនាយកវិទ្យាពាមជាំង លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ទាំងអស់ដែលបានរៀបចំទទួល និងស្វាគមន៍ក្រុមការងារយ៉ាងកក់ក្តៅ។ មុនពេលចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនដល់លោកគ្រូ អ្នកគ្រូ និងប្អូនៗ និងសិស្សានុសិស្សលោក ឡុង ដានី សង្ខេបអំពីប្រវត្តិមជ្ឈមណ្ឌលឯកសារកោះថ្ម គឺត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ដែលមានទីតាំងស្ថិតនៅក្នុងសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម។ ការបើកដំណើរការមជ្ឈមណ្ឌលឯកសារកោះថ្មមានគោលបំណងដូចខាងក្រោម ៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០។

២) ពង្រឹងការកសាងសន្តិភាព និងទប់ស្កាត់ជម្លោះតាមរយៈកម្មវិធីអប់រំជាឱកាសសម្រាប់យុវជនរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងការចូលរួម។

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យចែករំលែក និងបង្រៀនក្មេងៗនូវបទពិសោធន៍របស់ពួកគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។

៤) ប្រមែប្រមូលចងក្រងរឿងរ៉ាវ និងបទពិសោធន៍ពីអ្នករស់រានមានជីវិតដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម។



នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សចំនួន ១៩០នាក់ ក្នុងនោះមានស្រី១០០នាក់ នៅវិទ្យាល័យពាមជាំង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



៥) ជួយសម្របសម្រួលលើកគម្រោងលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាចុងក្រោយ លោក ឡុង ដានី បានបន្ថែមថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ គឺជាព្រះរាជសំណេរដើម និងមិនបានកែសម្រួល ដោយឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព និងសេចក្តីថ្លៃថ្នូរ ក្នុងអំឡុងពេលដែលព្រះអង្គអមព្រះរាជដំណើរសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ យាងដំណើរតាមយន្តហោះចេញពីទីក្រុងប៉េកាំង ទៅកាន់ទីក្រុងហាណូយ និងទីក្រុងដុងហ្វយ ខេត្តក័ងប៊ិញនៃប្រទេសវៀតណាម និងយាងបន្តដោយរថយន្តតាមបណ្តោយផ្លូវលំហូជីមិញទៅកាន់ខេត្តសៀមរាប ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៣។ ព្រះរាជដំណើររបស់ព្រះអង្គទាំងទ្វេដែលត្រូវចំណាយពេលជាងមួយខែនេះ បានបង្ហាញពីសេចក្តីថ្លៃថ្នូរ និងភាពទន់ភ្លន់របស់ព្រះមហាក្សត្រី ទោះជាព្រះរាជដំណើររបស់ព្រះអង្គស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍នាពេលនោះក្តី។ ព្រះមហាក្សត្រី គឺជាសាក្សីផ្ទាល់ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងរយៈកាលជាង៧ទសវត្សរ៍កន្លងមក ហើយព្រះអង្គ គឺជាឥស្សរជនប្រវត្តិសាស្ត្រដ៏លេចធ្លោមួយព្រះអង្គក្នុងអំឡុងពេលនោះ។ ព្រះរាជសំណេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ទ្រង់ផ្តល់នូវព្រះរាជតម្រិះសង្ខេបអំពីដំពូកដ៏សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកព្រៃឈរ ទទួលបានសៀវភៅ

## «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

*លី ដេវីត*



នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក ស៊ាង ចិន្តា, ទូច វណ្ណេត, សាំង ចាន់ធូ និង លី ដេវីត បន្តចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០នាក់ នៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក ស៊ាង ចិន្តា, ទូច វណ្ណេត, សាំង ចាន់ធូ និង លី ដេវីត បន្តចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០នាក់ រស់នៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

នៅក្នុងឱកាសនោះ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បង្ហាញអំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរ និងជាស្នាព្រះហស្តផ្ទាល់

របស់ហ្លួងម៉ែ ក្នុងព្រះរាជដំណើរអមសម្តេចព្រះនរោត្តម សីហនុយាងមកកាន់តំបន់រំដោះនៃប្រទេសកម្ពុជា។ ខណៈនោះដែរ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានចូលរួមនៅក្នុងកម្មវិធីនេះ បានរំឭកអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងរឿងរ៉ាវដែលបានកើតមានឡើងនៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បង្ហាញអារម្មណ៍រំភើប និងរំឭកអំពីបទពិសោធន៍ដែលខ្លួនបានឆ្លងកាត់សង្គ្រាម និងរបបខ្មែរក្រហម ដូចខាងក្រោម ៖

**ទ៉ា គីមអៀន** អាយុ៦២ឆ្នាំ រស់នៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ចែករំលែកការចងចាំអំពីដំណើរជីវិតរបស់ខ្លួនក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហម បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ថា «កាលពីកុមារ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះខ្ញុំពេញវ័យនៅពេលដែលសង្គ្រាមបានផ្ទុះឡើង។ នៅឆ្នាំ១៩៧៣ ពេលដែលសង្គ្រាមបានផ្ទុះឡើងខ្លាំង ខ្ញុំត្រូវបានជ្រើសរើសចូលធ្វើការនៅកងចល័តនៅក្នុងតំបន់រំដោះម្តុំព្រៃស្រឡាច។ កាលនោះមិនមានប្រជាជនរស់នៅជិតផ្លូវជាតិទេ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅលើកដីនៅតំបន់បឹងធំ និងការដ្ឋានមួយចំនួនទៀតនៅក្នុងស្រុកព្រៃឈរ។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដកទៅធ្វើការងារនៅចម្ការកៅស៊ូតំបន់ស្វាយមាស ស្រុកចំការលើ ខេត្តកំពង់ចាម។ នៅចម្ការកៅស៊ូ ខ្ញុំត្រូវបានបង្រៀនឲ្យចៀរជ័រកៅស៊ូ និងដាំដំណាំជាច្រើនមុខទៀត។ នៅក្នុងឆ្នាំ១៩៧៧ នៅពេលកម្មាភិបាលខ្មែរក្រហមភូមិភាគនិរតីចូលមក មនុស្សជាច្រើនត្រូវបានស្រាវជ្រាវ និងយកទៅសម្លាប់ចោល។ ពេលខ្លះកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី បានចុះមកចាប់មនុស្សយកទៅសម្លាប់ចោលនៅក្នុងចម្ការកៅស៊ូជ្រៅៗផងដែរ។ ខ្ញុំបានរួចជីវិតពីការចុះចាប់សម្លាប់នាពេលនោះ និងវិលត្រឡប់មករស់នៅភូមិកំណើតវិញ»។

**ឯម បោយ** អាយុ៦០ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម រំឭកឡើងពីការចងចាំនៅពេលកើតសង្គ្រាម និងបទពិសោធន៍ក្នុងរបបខ្មែរក្រហមថា «នៅពេលសង្គ្រាម ខ្ញុំ និងឪពុកម្តាយ រត់គេចខ្លួនពីកន្លែងមួយទៅកន្លែងមួយ ពីព្រោះតែការភ័យខ្លាចការទម្លាក់គ្រាប់បែក និងការបាញ់ផ្លោងដាក់គ្នា។ នៅឆ្នាំ១៩៧៥ ខ្ញុំធំដឹងក្តី។ អ្វីដែលខ្ញុំចងចាំមិនភ្លេចនាពេលនោះ គឺខ្មែរក្រហមបានឲ្យខ្ញុំទៅដកស្មៅនៅវាលស្រែ និងឲ្យហូបមិនគ្រប់គ្រាន់។ ក្នុងកងខ្ញុំ មានគ្នាប្រហែល៤០នាក់។ ពេលវេលាធ្វើការ គឺចាប់ផ្តើមពីមេឃភ្លឺរហូតដល់ល្ងាច។ បន្ថែមលើការងារដកស្មៅ ខ្ញុំ និងអ្នកផ្សេងទៀត ត្រូវទៅចាប់កណ្តុរនៅតាមវាលស្រែ។ បន្ទាប់ពីចាប់បាន ខ្ញុំត្រូវយកកណ្តុរនោះទៅបង្ហាញខ្មែរក្រហមជាភស្តុតាង។ ក្រោយមក ខ្ញុំរួចផុតពីទុក្ខវេទនា និងការស្លាប់ក្នុងរបបខ្មែរក្រហម»។

**វ៉ែម ម៉ន** អាយុ៧៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាមលើកឡើងអំពីការចងចាំរបស់ខ្លួន បន្ទាប់ពីទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ថា «ខ្ញុំកើតនៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ នេះតែម្តង។ កាលនៅពីក្មេង ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី៤ នៅសង្គមចាស់។ បន្ទាប់មក ខ្ញុំឈប់រៀនដើម្បីជួយធ្វើការងារឪពុកម្តាយ។ នៅឆ្នាំ១៩៧០ ក៏កើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ខ្ញុំដឹងអំពីព្រឹត្តិការណ៍រដ្ឋប្រហាររបស់លន់ នល់។ បន្ទាប់មក សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម បានផ្ទុះឡើង។ ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម តែងតែវាយប្រយុទ្ធគ្នានៅជិតផ្សារព្រៃទទឹង។ នៅពេលសង្គ្រាមផ្ទុះកាន់តែខ្លាំងឡើង ខ្ញុំនិងគ្រួសាររត់គេចខ្លួនទៅស្រុកកងមាស។ នៅឆ្នាំ១៩៧៥

ខ្ញុំបានវិលត្រឡប់មករស់នៅភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៦ សហករណ៍ត្រូវបានបង្កើតឡើង។ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើការងារនៅកងចល័តបុរស ដូចជា ធ្វើស្រែ លើកទំនប់ និងការងារផ្សេងៗទៀត។ ការហូបចុករបស់ខ្ញុំគឺមិនគ្រប់គ្រាន់ទេ។ នៅឆ្នាំ១៩៧៨ ប្រជាជននៅក្នុងភូមិព្រីងបីដើម ត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចាប់យកទៅសម្លាប់ជាបន្តបន្ទាប់។ ខ្ញុំរួចផុតពីការចាប់យកទៅសម្លាប់នាគ្រានោះ។ ខ្ញុំចងចាំអំពីរឿងរ៉ាវទាំងនេះ បន្ទាប់ពីឃើញចំណងជើង «សាក្សីប្រវត្តិសាស្ត្រ» និងឃើញរូបភាពក្នុងសៀវភៅនេះ»។







នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក ស៊ាង ចិន្តា, ទូច វណ្ណេត, សាំង ចាន់ធូ និង លី ដេវីត បន្តចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០នាក់ នៅភូមិព្រីងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ស៊ាង ចិន្តា



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក ស៊ាង ចិន្តា, សាំង ចាន់ធូ និង លី ដេវីត ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧០នាក់ ដែលរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

បន្ទាប់ពីបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបើកមើលរូបភាព និងអានខ្លឹមសារ ដែលរំឭកអំពីបទពិសោធន៍ដែលពួកគាត់ធ្លាប់ឆ្លងកាត់នៅគ្រាដ៏លំបាកនៅក្នុងរបប

ខ្មែរក្រហម។ ភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម មានទីតាំងស្ថិតនៅតាមដងទន្លេមេគង្គ និងមានចម្ងាយប្រហែល១៥គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ចាម។ ចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ ភូមិចំការសាមសិបគឺជាសមរភូមិប្រទាញប្រទង់រវាងកងទ័ពរំដោះខ្មែរក្រហម និងទាហានលន់នល់។ ទាហានលន់នល់ តែងតែបើកការប្រយុទ្ធនៅក្នុងភូមិសាស្ត្រភូមិចំការសាមសិប និងធ្វើឲ្យឆេះផ្ទះអ្នកភូមិដែលបណ្ដាលមកពីការទម្លាក់គ្រាប់បែក។ ក្នុងគ្រាដែលការប្រយុទ្ធគ្នាកំពុងផ្ទុះឡើង អ្នកភូមិមួយចំនួនរត់ភៀសខ្លួនឆ្លងទន្លេទៅកាន់ដីហែដែលជាតំបន់រំដោះខ្មែរក្រហម ចំណែកអ្នកភូមិមួយចំនួនទៀតរត់ចូលទីរួមខេត្តកំពង់ចាម ដែលគ្រប់គ្រងដោយលន់នល់។ ការប្រយុទ្ធ និងប្រទាញប្រទង់នេះបានបញ្ចប់នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមបានវាយយកឈ្នះទៅលើទាហានលន់នល់ និងរំដោះភូមិចំការសាមសិបនៅចុងឆ្នាំ១៩៧២។

លោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ពន្យល់បន្ថែមអំពីសារសំខាន់ និងការផ្សារភ្ជាប់បរិបទប្រវត្តិសាស្ត្រមូលដ្ឋានដែលកើតឡើងនៅភូមិចំការសាមសិប និងបរិបទប្រវត្តិសាស្ត្រប្រទេសកម្ពុជាជាមួយសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រ នរោត្ដម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរ ទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រ នរោត្ដម សីហនុ ព្រះវររាជមាតាជាតិខ្មែរ គឺជាព្រះរាជសំណេរដើម និងមិនកែសម្រួលដែលបង្ហាញអំពីព្រះរាជដំណើរអមព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ យាងមកប្រទេសកម្ពុជា នៅឆ្នាំ១៩៧៣។

លោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានឃុំគគរ ថ្លែងអំណរគុណដល់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលចុះមកចែកសៀវភៅប្រវត្តិសាស្ត្រដ៏មានតម្លៃនាពេលនេះ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប នៅតែចងចាំអំពីទុក្ខវេទនាការបាត់បង់ឪពុកម្ដាយ បងប្អូន និងសាច់ញាតិក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហម។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះនឹងរំឭកការចងចាំ និងការឈ្វេងយល់បន្ថែមអំពីជំពូកប្រវត្តិ-សាស្ត្រកម្ពុជា ដែលចេញពីព្រះរាជកំណត់ហេតុរបស់ហ្វូងម៉ែ។ បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានបង្ហាញចំណាប់អារម្មណ៍ និងទស្សនយល់ឃើញដូចខាងក្រោម៖

**ម៉ម ស្រឿន** អាយុ៧៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិបឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម រៀបរាប់ថា «ខ្ញុំដឹងពីព្រឹត្តិការណ៍ដែលកើតឡើងក្នុងពេលសង្គ្រាមតាមរយៈសៀវភៅនេះ និងបានរំឭកខ្ញុំពីការរត់គេចខ្លួនពីការវាយប្រយុទ្ធគ្នានៅឆ្នាំ១៩៧៣។ ភូមិចំការសាមសិបនេះគឺជាសមរភូមិក្ដៅនៅពេលនោះ។ ខ្ញុំរងនូវទុក្ខលំបាក និងការរត់គេចខ្លួនច្រើនលើកច្រើនសារ»។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រ នរោត្ដម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**ប៊ុន សេងហាន** អាយុ៧៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម បានលើកឡើងថា «នៅពេលបើកមើលរូបភាពក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះ ខ្ញុំនឹកឃើញពេលដែលខ្ញុំ និងគ្រួសាររត់គេចខ្លួនចេញពីការទម្លាក់គ្រាប់នៅក្នុងភូមិចំការសាមសិបក្នុងឆ្នាំ១៩៧៣។ បន្ទាប់មកផ្ទះរបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀតត្រូវបានភ្លើងឆេះអស់។ ពេលនោះគឺពិតជាលំបាកខ្លាំងណាស់ ដោយសារតែមានសង្គ្រាមកើតឡើងនៅគ្រប់ទីកន្លែង។ ខ្ញុំនឹងយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ទៅឲ្យចៅរបស់ខ្ញុំអានឲ្យខ្ញុំស្តាប់ ដើម្បីអាចដឹងអំពីរឿងរ៉ាវនាពេលនោះបន្ថែមទៀត ព្រោះភ្នែករបស់ខ្ញុំងងឹតមើលមិនឃើញទេ»។





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សានុសិស្សចំនួន ២៨០នាក់ នៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង ទទួលបានសៀវភៅ

## «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

**សាំង ចាន់ធូ និង ទូច វណ្ណោត**



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន២៨០នាក់ នៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង ។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យហ្វូងម៉ៃ ចំនួន២៨០ក្បាលដល់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់១២ នៃវិទ្យាល័យ ហ៊ុនសែន កងតាណឹង។

វិទ្យាល័យ ហ៊ុនសែនកងតាណឹង ស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គ នៅក្នុងស្រុកកងមាស ខេត្តកំពង់ចាម។ វិទ្យាល័យនេះមានទីធ្លាធំទូលាយ បង្កើតឡើងនៅក្នុងឆ្នាំ២០០៣ និងមានសិស្សានុសិស្សសរុបចំនួនជាង១០០០នាក់កំពុងសិក្សា ដែលក្នុងនោះមានសិស្សរៀនថ្នាក់ទី១២ សរុបចំនួន២៨០នាក់។

ជាកិច្ចចាប់ផ្តើម លោក ធន់ ធរ នាយកវិទ្យាល័យ ហ៊ុនសែន កងតាណឹង និងគណៈគ្រប់គ្រងវិទ្យាល័យ



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន២៨០នាក់នៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង ។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ទទួលស្វាគមន៍ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងថ្លែងអំណរគុណដល់ការចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នាពេលនេះ ដែលជាពេលវេលាដ៏សំខាន់សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ត្រៀមប្រឡងមធ្យមសិក្សាទុតិយភូមិ។ បន្ទាប់មក លោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានធ្វើការណែនាំខ្លួន និងក្រុមការងាររួមមាន ទូច វណ្ណេត, សាំង ចាន់ធូ និង លី ដេវីត។

មុនចាប់ផ្ដើមចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» លោក ស៊ាង ចិន្ដា លើកឡើងអំពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម មានតួនាទី និងចុះអនុវត្តកិច្ចការងារស្នូលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅតាមមូលដ្ឋាន ក្នុងការចងក្រងឯកសារ អប់រំ និងផ្សព្វផ្សាយឯកសារស្ដីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ឬប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីការផ្ដល់បទបង្ហាញខ្លីអំពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម លោក ស៊ាង ចិន្ដា និងក្រុមការងារចាប់ផ្ដើមចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» និងពន្យល់អំពីសារសំខាន់នៃសៀវភៅនេះ ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរសម្រាប់សិស្សានុសិស្ស ដែលជាក្មេងជំនាន់ក្រោយដើម្បីធ្វើការសិក្សាឈ្វេងយល់ចេញពីព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ

សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ យាងមកកាន់តំបន់រំដោះនៃប្រទេសកម្ពុជា នៅឆ្នាំ១៩៧៣។

សិស្សានុសិស្សមានរយៈពេល២០នាទី ដើម្បីបើកមើល និងអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»។ បន្ទាប់មកសិស្សឈ្មោះ រី ស្រីម៉ុម អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គម បានក្រោកឈរ និងអាននូវទំព័រទី១៧ ដែលបង្ហាញអំពីកាលបរិច្ឆេទ៖ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៣។ ស្រីម៉ុម លើកឡើងថា «សំណេរដែលលើកឡើងនៅ ទំព័រទី១៧ នេះ គឺបង្ហាញអំពីកាលបរិច្ឆេទចេញដំណើររបស់ទ្រង់ទាំងទ្វេ និងមនុស្សដែល ហ្លួងម៉ែបានជួបនាពេលនោះ។ ខ្លឹមសារដែលខ្ញុំទើបតែដឹងនាពេលនេះ គឺការដឹងអំពីព្រះនាមរបស់រាជបុត្រា ទាំង២ព្រះអង្គរបស់ ហ្លួងម៉ែ។ ខ្ញុំពិតជាសប្បាយចិត្តដែលទទួលបានសៀវភៅប្រវត្តិសាស្ត្រដ៏សំខាន់នេះ។ ខ្ញុំនឹងអានសៀវភៅនេះឲ្យចប់។

បន្ទាប់ពីទទួលបានសៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» សិស្សានុសិស្សបានបង្ហាញចំណាប់អារម្មណ៍ និងទស្សនយល់ឃើញ ដូចខាងក្រោម៖

**យ៉ា ស្រីមាស** អាយុ១៩ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង លើកឡើងថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ពិតជាមានតម្លៃណាស់សម្រាប់ខ្ញុំដែលជាក្មេងជំនាន់ក្រោយ និងកំពុងត្រៀមប្រឡង ពីព្រោះ ហ្លួងម៉ែព្រះរាជសំណេរយ៉ាងក្បោះក្បាយអំពីកាលបរិច្ឆេទ មនុស្សដែលព្រះអង្គជួប និងទីតាំងនីមួយៗដែលព្រះអង្គយាងទៅដល់។ រឿងរ៉ាវដែល ហ្លួងម៉ែកត់ត្រានាគ្រានោះ គឺជារឿងរ៉ាវដ៏សំខាន់និងកម្រដែលខ្ញុំជាក្មេងជំនាន់ក្រោយមិនអាចដឹង ឬមិនដែលបានដឹងពីមុនមក»។

**អឿ ចិនសាង** អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង លើកឡើងថា «ខ្ញុំមានអារម្មណ៍ត្រេកអរយ៉ាងខ្លាំងពេលទទួលបានសៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់របស់ ហ្លួងម៉ែ ពីព្រោះខ្ញុំអាចដឹងពីរឿងរ៉ាវជាច្រើនដែលជាបទពិសោធន៍ពិតរបស់ ហ្លួងម៉ែ និងសម្តេចតា ដែលទ្រង់ទាំងទ្វេបានយាងចូលប្រទេសនៅក្នុងឆ្នាំ១៩៧៣។







ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន២៨០នាក់ នៃវិទ្យាល័យ ហ៊ុន សែន កងតាណឹង ។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# និស្សិតផ្នែកប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

សាំង ចាន់ធូ



និស្សិតឆ្នាំទី៤ ឯកទេសប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ សាំង ចាន់ធូ / មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅរសៀលថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ ហៃ រក្សា និង អ៊ុន ធីតា គឺជានិស្សិតឆ្នាំទី៤ ផ្នែកប្រវត្តិវិទ្យា មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ធ្វើទស្សនកិច្ចសិក្សា និងស្រាវជ្រាវមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ និស្សិតទាំងពីរទទួលបានកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅពីក្រុមការងារដែលបានណែនាំអំពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងកិច្ចការងារអប់រំស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដើរទស្សនាពិព័រណ៍បណ្ណាល័យខ្មែរក្រហម បន្ទប់ឯកសារ និងបន្ទប់គម្រោងសូត្រចាម។

ក្នុងដំណើរទស្សនកិច្ចនៅថ្ងៃនេះ និស្សិតទាំងពីរបានចាប់អារម្មណ៍បន្ទប់ឯកសារ ដែលទាក់ទងនឹងប្រធានបទកិច្ចការស្រាវជ្រាវរបស់ខ្លួន។ ហៃ រក្សា បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ «ការរៀបការដោយបង្ខំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ»។ ចំណែក អ៊ុន ធីតា សិក្សាស្រាវជ្រាវអំពី «ការកាប់សម្លាប់ប្រជាជន នៅក្នុង

សម័យកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧១៩៧៩)»។

បន្ទាប់ពីកិច្ចពិភាក្សាបានបញ្ចប់ លោក លី ដេវីត បានពន្យល់បង្ហាញអំពីពិព័រណ៍ព្រះឆាយាលក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៍ «ក្តីសុបិនកម្ពុជា» រៀបចំដោយ «ព្រះរាជបណ្ណាល័យហ្វូងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងផ្តល់ជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូននិស្សិតទាំងពីរផងដែរ។

ជាចុងបញ្ចប់ និស្សិត ហៃ រក្សា និង អ៊ុន ធីតា បានថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានចំណាយពេលវេលាដឹកនាំទស្សនាពិព័រណ៍, ផ្តល់ព័ត៌មាន និងឯកសារតាមការស្នើសុំរបស់ខ្លួន។







និស្សិតឆ្នាំទី៤ ឯកទេសប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (សាំង ចាន់ធូ / មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាពនិងសិទ្ធិមនុស្ស» សម្រាប់សិស្សវិទ្យាល័យស្រែណូយ

សួត វិចិត្រ



នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាពនិងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤១នាក់ មកពីវិទ្យាល័យស្រែណូយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាពនិងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤១នាក់ មកពីវិទ្យាល័យស្រែណូយ។ ដំណើរទស្សនកិច្ចនេះបានចាប់ផ្តើមឡើងដោយការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅអតីតផ្ទះប្រជុំតាម៉ុកនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្នត្រូវបានប្រែក្លាយជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ព្រមទាំងការធ្វើដំណើរទស្សនកិច្ចនៅតាមតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដែលបន្សល់ពីសម័យកាលតស៊ូប្រដាប់អាវុធរបស់ខ្មែរក្រហម។ នៅក្នុងបទបង្ហាញនេះ សិស្សានុសិស្សក៏បានចូលរួមក្នុងការពិភាក្សា និង







នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាព និងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤១នាក់ មកពីវិទ្យាល័យស្រែណូយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចោទជាសំណួរថា «ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯងយ៉ាងច្រើនបែបនេះ? តើមេដឹកនាំសំខាន់ៗ ដូចជា ប៉ុល ពត និងមេដឹកនាំផ្សេងទៀតបានដឹង ឬបានចូលរួមក្នុងផែនការសម្លាប់ប្រជាជនដែរឬទេ?»។

នៅក្នុងផ្នែកពិភាក្សានេះ សិស្សានុសិស្សមួយចំនួននៅក្នុងក្រុម បានគិតទៅដល់អំពើឃោរឃៅដែលកើតចេញពីភាពស្អប់ខ្ពើម អំពើហិង្សា និងការរើសអើងគ្នាដោយសារតែភាពខុសគ្នានៃពណ៌សម្បុរ ពូជសាសន៍ សាសនា ឬនិន្នាការនយោបាយជាដើម។ អាស្រ័យហេតុនេះហើយ ព្រហ្មវិហារធម៌ទាំងបួន គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ក៏ត្រូវបានក្លាយជាផ្នែកមួយនៃការពិភាក្សាគ្នានេះដែរ។ បន្ទាប់មក សិស្សានុសិស្សក៏បានធ្វើដំណើរទៅទស្សនាផ្ទាល់នូវទីតាំងបូជាសព ប៉ុល ពត ដែលស្ថិតនៅក្បែរច្រកព្រំដែនអន្តរជាតិ ជាំ- សាង៉ាំ, កន្លែងបូជាសព សុន សេន និងក្រុមគ្រួសារ, ចេតិយតាម៉ុក និងសារមន្ទីរអតីតផ្ទះតាម៉ុក នៅក្នុងទីរួម

ស្រុកអន្លង់វែង។ ចុងបញ្ចប់ដំណើរទស្សនកិច្ចនេះ សិស្សានុសិស្សបានបង្ហាញពីចំណាប់អារម្មណ៍ និងការយល់ឃើញដូចខាងក្រោម ៖

**ភី ល័ក្ខ** ភេទស្រី អាយុ១៩ឆ្នាំ មានចំណាប់អារម្មណ៍ថា «ខ្ញុំពិតជាចង់ចូលរួមក្នុងដំណើរទស្សនកិច្ចនៅតាមទីតាំងប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែងតាំងពីដំបូង ដោយសារតែខ្ញុំចង់ឈ្វេងយល់ពីប្រវត្តិសាស្ត្រសម័យ ប៉ុល ពត។ នៅពេលខ្ញុំបានឃើញកុនឯកសារដែលចាក់បញ្ចាំងនៅផ្ទះប្រជុំរបស់ តាម៉ុក ខ្ញុំពិតជាមានអារម្មណ៍ពិបាកទទួលយកខ្លាំងណាស់លើអ្នកទោសដែលទទួលរងអំពើឃោរឃៅនាជំនាន់នោះ។ ក្នុងនាមយើងជាយុវជនម្នាក់ យើងត្រូវលុបបំបាត់ការប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ សាសនា ចេះរួបរួមសាមគ្គីគ្នា និងលុបបំបាត់អំពើហិង្សា ទាំងនៅក្នុងគ្រួសារ និងសង្គមជាតិ ដើម្បីឲ្យសង្គមជាតិរបស់យើងពោរពេញទៅដោយសន្តិភាព»។

**អ៊ីញ ស្រីនួច** ភេទស្រី អាយុ១៨ឆ្នាំ យល់ឃើញថា «ក្នុងដំណើរទស្សនកិច្ចនៅថ្ងៃនេះ ខ្ញុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រជាច្រើន ជាពិសេស គឺពីរបបខ្មែរក្រហម និងភាពឃោរឃៅនៃរបបនោះ។ ដូច្នេះដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ យើងត្រូវជួយផ្សព្វផ្សាយពីចំណេះដឹងនៃប្រវត្តិសាស្ត្រទៅកាន់មនុស្សជុំវិញខ្លួន»។

**ឈឿន សក្កជា** ភេទស្រី អាយុ១៨ឆ្នាំ និយាយថា «នៅក្នុងដំណើរទស្សនកិច្ចនេះ ខ្ញុំគិតថាល្អ ដែលអាចឲ្យខ្ញុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រ ហើយខ្ញុំចង់ឲ្យមិត្តភក្តិផ្សេងទៀតបានចូលរួមដូចខ្ញុំដែរ។ ខ្ញុំយល់ថា ដើម្បីទប់ស្កាត់នូវអំពើប្រល័យពូជសាសន៍នាពេលអនាគត គឺយើងមិនត្រូវរើសអើងគ្នា»។

**ហាក់ ណាលីន** ភេទស្រី អាយុ១៦ឆ្នាំ លើកឡើងថា «ទស្សនកិច្ចសិក្សានេះ បានធ្វើឲ្យខ្ញុំយល់ដឹងនូវរឿងរ៉ាវកាលពីពេលមុន ជាពិសេស គឺភូមិសាស្ត្រនៅក្នុងស្រុកអន្លង់វែង និងទីកន្លែងប្រវត្តិសាស្ត្រមួយចំនួនទៀត ដូចជាទីកន្លែងបូជាសព ប៉ុល ពត»។

**សុខ ស័ក្កណា** ភេទស្រី អាយុ១៨ឆ្នាំ ឲ្យដឹងថា «អ្វីដែលខ្ញុំចាប់អារម្មណ៍ជាងគេក្នុងដំណើរទស្សនកិច្ចនេះ គឺទីកន្លែងបូជាសព ប៉ុល ពត ដោយសារតែវាទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ដែលយុវជនម្នាក់ៗត្រូវទប់ស្កាត់»។

**ឡែន លី** ភេទប្រុស អាយុ២០ឆ្នាំ ប្រាប់ថា «ក្នុងនាមយើងជាយុវជនម្នាក់ គឺយើងត្រូវរួបរួមគ្នាដើម្បីទប់ស្កាត់នូវការប្រើប្រាស់អំពើហិង្សាដូចដែលធ្លាប់កើតមាននៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ។ ជាពិសេស យើងត្រូវតែខិតខំសិក្សារៀនសូត្រ ដើម្បីកសាងប្រទេសជាតិឲ្យមានការរីកចម្រើន។

**ចិន ចេក** ភេទប្រុស អាយុ២០ឆ្នាំ និយាយថា «ខ្ញុំទទួលបានចំណេះដឹងច្រើនពីទស្សនកិច្ចសិក្សានេះ គឺដឹងថាមេដឹកនាំ ប៉ុល ពតបានធ្វើអ្វីខ្លះ និងដឹងពីមូលហេតុដែលបណ្តាលឲ្យប្រជាជនខ្មែរស្លាប់បាត់បង់ជីវិត»។





នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាព និងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤១នាក់ មកពីវិទ្យាល័យស្រែណូយ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាអប់រំស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ -១៩៧៩)»

## និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូន សិស្សានុសិស្ស និងប្រជាជន នៅក្នុងសហគមន៍ភូមិក្រពើពីរក្រោម

ឡុង ដានី







នៅព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាអប់រំសហគមន៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩)» និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន ៤៦ក្បាល ជូនសិស្សានុសិស្សនិង ប្រជាជនរស់នៅសហគមន៍ក្នុងភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចែកសៀវភៅសាក្សីប្រវត្តិសាស្ត្រចំនួន៤៦ក្បាល និងរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩)» នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងកូនចៅជំនាន់ក្រោយចូលរួមសរុបចំនួន៤៦នាក់។

ជំបូងលោកស្រី ហែម ភាន់ អាយុ៦៤ឆ្នាំ គឺជាមេភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់មានប្រសាសន៍ថា «សព្វថ្ងៃភូមិក្រពើ

ពីរក្រោមមានប្រជាជនចំនួន២៤០គ្រួសារ ស្មើនឹងប្រជាជនសរុបចំនួន៩៥២នាក់។ ប្រជាជនរស់នៅក្នុងភូមិក្រពើពីរក្រោម ភាគច្រើនគឺជាអតីតកងទ័ពខ្មែរក្រហម និងក្រុមគ្រួសារ។ លោកស្រីមេភូមិ បានបន្តថា ថ្ងៃនេះខ្ញុំតំណាងឲ្យប្រជាពលរដ្ឋក្នុងភូមិក្រពើពីរក្រោមមានសេចក្តីសប្បាយរីករាយដែលក្រុមការងារមជ្ឈមណ្ឌលឯកសារ ផ្សះផ្សាវាលវែង បានចុះមកចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុរបស់ ហួងម៉ៃ ក្នុងពេលព្រះអង្គអមព្រះរាជដំណើរសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ពីទីក្រុងប៉េកាំង មកទីក្រុងហាណូយ ប្រទេសវៀតណាម និងបន្តដំណើរទៅកាន់ខេត្តសៀមរាប ប្រទេសកម្ពុជា នៅឆ្នាំ១៩៧៣»។ លោកស្រី បានលើកឡើងថា សូមបងប្អូនជួយចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនដែលបានឆ្លងកាត់សម័យសង្គ្រាម និងរបបខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ ដើម្បីបានយល់ដឹងកាន់តែច្បាស់ ពីព្រោះការរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គឺជាឱកាសល្អសម្រាប់បងប្អូនដដែក និងនិយាយរឿងរ៉ាវអំពីអតីតកាលប្រាប់ដល់កូនចៅជំនាន់ក្រោយ ដែលកើតមិនទាន់សម័យសង្គ្រាម។

ជាកិច្ចបន្តលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានជម្រាបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនដែលបានចូលរួមក្នុងវេទិកាអប់រំសហគមន៍ថា មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានបើកដំណើរការជាសាធារណៈនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណង ទី១) ធ្វើការស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រសង្គ្រាមនៅប្រទេសកម្ពុជាចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩០។ ទី២) ពង្រឹងការកសាងសន្តិភាព និងការការពារជម្លោះតាមរយៈកម្មវិធីអប់រំ ដែលនឹងផ្តល់ឱកាសសម្រាប់យុវជននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលបានចូលរួមរៀនសូត្រ។ ៣) លើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចែករំលែកបទពិសោធន៍របស់ពួកគាត់ក្នុងរបបខ្មែរក្រហមដល់យុវជនជំនាន់ក្រោយៗ ៤) ប្រមូលរឿងរ៉ាវជីវិត បទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

នៅខណៈនោះ លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញជាសង្ខេបអំពីរបបខ្មែរក្រហម ដូចជា ១) ការឡើងកាន់អំណាចរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ២) ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន, ៣) ការបំបាត់ផ្សារ និងរូបិយវត្ថុ, ៤) ការផ្សឹកព្រះសង្ឃ និងកម្ទេចវត្តអារាម, ៥) ការបិទសាលារៀន, ៦) ការបង្កើតសហករណ៍, ៧) ការបំបែកក្រុមគ្រួសារ និងការផ្តាច់ទំនាក់ទំនងក្នុងគ្រួសារ, ៨) ការសម្លាប់បញ្ញវន្តមន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់។

បន្ថែមលើនេះ លោក ឡុង ដានី ក៏បានបង្ហាញនូវផលប៉ះពាល់មកលើប្រជាជន និងសង្គមកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩មានដូចខាងក្រោម៖

១) បន្សល់ទុកស្ត្រីមេម៉ាយ និងកុមារកំព្រារាប់រយពាន់នាក់។

២) ប្រជាជនខ្មែររាប់សែននាក់បានរត់ចេញពីប្រទេស ហើយបានក្លាយជាជនភៀសខ្លួន។

៣) គ្រាប់មីនរាប់លានគ្រាប់ត្រូវបានបង្កប់ដោយកងទ័ពនៃភាគីជម្លោះដែលបណ្តាលឲ្យប្រជាជនរាប់ពាន់នាក់ស្លាប់ និងពិការចាប់តាំងពីឆ្នាំ១៩៧៩ រហូតមក។

៤) ប្រជាជនខ្មែរភាគច្រើនមានបញ្ហាជំងឺផ្លូវចិត្តដោយសារតែបាត់បង់សមាជិកគ្រួសារ។

៥) សេដ្ឋកិច្ចធ្លាក់ដល់កម្រិតសូន្យ។

៦) បាត់បង់ធនធានមនុស្សដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ។

បន្ទាប់មកក្រុមការងារបានបែងចែកក្រុមអ្នកចូលរួមវេទិកាអប់រំសហគមន៍ជា៥ក្រុម ដោយក្នុងក្រុមនីមួយៗ មានសមាសភាពទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយ ដើម្បីសន្ទនាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាពិសេសគឺរឿងរ៉ាវរបស់

អ្នករស់រានមានជីវិតនៅក្នុងរបបខ្មែរក្រហមម្នាក់ៗ។

**សមាសភាពក្នុងក្រុមនីមួយៗមានដូចខាងក្រោម ៖**

**ក្រុមទី១)** មានអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងយុវជនចំនួន៩ នាក់

**ក្រុមទី២)** មានអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងយុវជនចំនួន៩ នាក់

**ក្រុមទី៣)** មានអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងយុវជនចំនួន៩ នាក់

**ក្រុមទី៤** មានអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងយុវជនចំនួន៩ នាក់

**ក្រុមទី៥)** មានអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងយុវជនចំនួន១០នាក់

លោកស្រីមេភូមិ ហែម ភាន់ មានប្រសាសន៍ថា «ខ្ញុំពិតជាមានការសប្បាយរីករាយខ្លាំងណាស់នៅពេលដែលខ្ញុំ និងបងប្អូនប្រជាពលរដ្ឋបកស្រាយរឿងរ៉ាវពិតរបស់ខ្លួនប្រាប់ទៅដល់ក្មួយៗដែលជាក្មេងជំនាន់ក្រោយឲ្យបានដឹង និងអនុញ្ញាតឲ្យក្មេងៗបានសួរនាំ។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ពេលប្រទេសកម្ពុជា ទទួលបានសន្តិភាពពេញលេញ ប្រជាជនមានការហូបចុកគ្រប់គ្រាន់ មានភ្លើងអគ្គិសនី។ ខ្ញុំសូមសំណូមពរឲ្យកូនចៅជំនាន់ក្រោយតស៊ូរៀនសូត្រដើម្បីគ្រួសារ និងប្រទេសជាតិ»។

ចំណែក លោក ប្រាក់ ហ៊ីម មានប្រសាសន៍ថា ថ្ងៃនេះខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយដែលបានរៀបរាប់អំពីការលំបាកវេទនាកាលពីអតីតកាល ដូចជា សម័យសង្គ្រាម៥ឆ្នាំ ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥, របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការធ្វើសង្គ្រាមនៅតាមព្រំដែនក្រោយឆ្នាំ១៩៧៩។ ថ្ងៃនេះខ្ញុំបានរំឭកឡើងវិញអំពីការលំបាកវេទនា ដូចជាការរស់នៅក្នុងព្រៃ។ ពេលប្រយុទ្ធម្តងៗ ខ្ញុំមិនដែលគិតថាមានជីវិតរស់នៅឡើយ ហើយពេលខ្លះអត់បាយហូប ហើយពេលឈឺថ្កាត់ម្តងៗគ្មានថ្នាំសង្កូវសម្រាប់ព្យាបាលឡើយ។ ខ្ញុំសប្បាយចិត្តពេលដែលក្រុមការងារមជ្ឈមណ្ឌលឯកសារផ្សះផ្សារវាលវែង ចុះមកធ្វើវេទិកាអប់រំប្រវត្តិសាស្ត្រសហគមន៍។

ដោយឡែក សិស្សឈ្មោះ សន ស្រីនីត បង្ហាញចំណាប់អារម្មណ៍ថា បើប្រៀបធៀបពីសម័យមុន និងសម័យនេះ គឺខុសគ្នាច្រើនណាស់ ពីសម័យមុនក្មេងៗត្រូវខ្មែរក្រហមប្រើឲ្យធ្វើការហួសកម្លាំង និងមិនឲ្យអាហារហូបគ្រប់គ្រាន់។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តខ្លាំងណាស់នៅពេលដែលបានស្តាប់រឿងរ៉ាវរបស់លោកតា លោកយាយ ដែលធ្វើឲ្យខ្ញុំបានដឹងនូវរឿងរ៉ាវពិតរបស់ពួកគាត់។



នៅព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាអប់រំសហគមន៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩)» និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន៤៦ក្បាល ជូនសិស្សានុសិស្ស និងប្រជាជនរស់នៅសហគមន៍ក្នុងភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

**លី ដេវីត**








នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងស្រុកកោះសូទិន និងយុវជនមកពីស្រុកកំពង់សៀម ចំនួន៥០នាក់ៗ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ( ១៩៧៥-១៩៧៩) និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នកចូលរួមដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងស្រុកកោះសូទិន និងយុវជន-យុវនារីមកពីស្រុកកំពង់សៀម ចំនួន៥០នាក់ៗ វេទិកាអប់រំសហគមន៍នៅខែកញ្ញានេះ គឺផ្តោតសំខាន់ទៅលើការស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមៗ

ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានថ្លែងបើក

វេទិកា និងលើកឡើងអំពីបរិបទប្រវត្តិសាស្ត្រចាប់ពីរដ្ឋប្រហារ លន់ នល់ ឆ្នាំ១៩៧០ ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម និងជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម។ ក្រោយការធ្វើបទបង្ហាញចប់លោក ស៊ាង ចិន្តា ឆ្លៀតយកឱកាសចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់យុវជនដែលបានចូលរួមនៅក្នុងថ្ងៃនេះ។

បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ រួចយុវជនទាំងអស់ត្រូវបានចែកជាពីរក្រុមដើម្បីស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានចូលរួមកម្មវិធីថ្ងៃនេះ និងធ្វើដំណើរតាមរទេះសេះទៅកាន់ស្តូបគោរពវិញ្ញាណក្ខន្ធអ្នកដែលបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សដែលបានចូលរួមនៅក្នុងវេទិកាអប់រំសហគមន៍៖

**ទ្រី ចាន់ដេត** អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១០ បានលើកឡើងថា «ខ្ញុំពិតជាមានអារម្មណ៍រីករាយបន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលជាព្រះរាជនិពន្ធផ្ទាល់របស់ហ្លួងម៉ែ។ ខ្ញុំយល់ឃើញថា សៀវភៅនេះគួរត្រូវបានចែកជូនសិស្សនៅតាមសាលារៀនផ្សេងៗទៀតដើម្បីអាន និងបង្កើននូវចំណេះ។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីសៀវភៅនេះ ទៅចែករំលែកជាមួយអ្នកស្រុក អ្នកភូមិ និងមិត្តភក្តិនៅសាលា។ ខ្ញុំសំណូមពរទៅព្រះរាជបណ្ណាល័យ ហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់កម្មវិធីសិក្សាបន្ថែមដើម្បីឲ្យសិស្សឈ្វេងយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ។ ខ្ញុំបានស្តាប់រឿងរ៉ាវរបស់អ្នកគ្រូ ម៉ៅ វណ្ណា និងបានដឹងពីប្រវត្តិដ៏លំបាករបស់អ្នកគ្រូ ដែលបាត់បង់សាច់ញាតិក្រុមគ្រួសារស្ទើរតែទាំងអស់»។

**ខុម រត្តនា** អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១០ រៀបរាប់ថា «ខ្ញុំចងចាំនូវការពន្យល់របស់លោកអ៊ំ គឹម សាន្ត ដែលបានរៀបរាប់ពីការដឹកនាំនៅសម័យខ្មែរក្រហម។ សម្រាប់ចំណេះដឹងដែលខ្ញុំទទួលបានពីវេទិកានេះ ខ្ញុំនឹងយកទៅចែករំលែកក្នុងសហគមន៍តាមរយៈការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឲ្យប្អូនៗជំនាន់ក្រោយបានយល់ដឹង។ ខ្ញុំនៅតែបន្តនិយាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់មជ្ឈដ្ឋានជុំវិញខ្លួន។ ខ្ញុំសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តបង្កើតដំណើរទស្សនកិច្ចសិក្សាដល់សិស្ស ដើម្បីជួបពិភាក្សាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យបានច្រើនៗ។ ជាពិសេសខ្ញុំពិតជាមានកិត្តិយសខ្លាំងណាស់ដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុផ្ទាល់របស់សម្តេចយាយ»។



នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងស្រុកកោះសូទិន និងយុវជនមកពីស្រុកកំពង់សៀម ចំនួន៥០នាក់។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ




«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។




មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។










តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។







ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរស័ព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org







សូមអរគុណ!

# ប្តីខ្ញុំស្លាប់ពេលជម្លៀសទៅបាត់ដំបង

ថុន ស្រីពេជ្រ

ខ្ញុំឈ្មោះ ស៊ិន លន ភេទស្រី អាយុ៦៦ឆ្នាំ រស់នៅភូមិកំពង់អាទុង សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ គីម ហេង និងម្តាយឈ្មោះ ទើប ឡាច។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ក្នុងនោះស្រី២នាក់។ បងប្រុសរបស់ខ្ញុំចំនួន២នាក់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅឆ្នាំ១៩៧៥ ដោយសារតែពួកគាត់ទាំងពីរនាក់គឺជាទាហានលន់ នល់។

ក្រោយខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅភូមិខ្ទោក ឃុំពពឺស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ ខ្ញុំត្រូវបានអង្គការប្រើឲ្យធ្វើស្រែ ជីកប្រឡាយ និងលើកប្រព័ន្ធភ្លឺស្រែ។ ដំបូងឡើយ ការងារទាំងអស់នេះពុំសូវជាហត់ប៉ុន្មានទេ ប៉ុន្តែក្រោយមកទៀតខ្មែរក្រហមដាក់វេនឲ្យប្រជាជនដើម្បីធ្វើការបន្ថែមម៉ោងនៅពេលយប់ទៀត។ វេនធ្វើការរបស់ខ្ញុំគឺចាប់ពីម៉ោង១១ រហូតដល់ម៉ោង២យប់ ទើបខ្ញុំបានឈប់សម្រាក។ ដោយសារតែមានការនឿយហត់ និងអស់កម្លាំងខ្លាំងពេក បណ្តាលឲ្យខ្ញុំធ្លាក់ខ្លួនឈឺ និងរាករូសធ្ងន់ធ្ងរ។ រំពេចនោះ អ្នកដែលស្នាក់នៅជាមួយខ្ញុំ បានរាយការណ៍ទៅកាន់ប្រធាន



ស៊ិន លន ភេទស្រី អាយុ៦៦ឆ្នាំ រស់នៅភូមិកំពង់អាទុង សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុម ដើម្បីយកខ្ញុំទៅមន្ទីរពេទ្យ។ គ្រូពេទ្យបានចាក់ថ្នាំឲ្យខ្ញុំមួយម្ជុល និងឲ្យថ្នាំខ្ញុំយកមកលេប។ ខ្ញុំបានធូរស្រាលពីជំងឺរាករូស ប៉ុន្តែខ្ញុំនៅមិនទាន់មានកម្លាំងធ្វើការនៅឡើយ។ ប្រធានក្រុមក៏បានអនុញ្ញាតឲ្យខ្ញុំបានឈប់សម្រាកចំនួនកន្លះខែ ដោយយល់ឃើញថា ខ្ញុំគឺជាមនុស្សដែលឧស្សាហ៍ព្យាយាមក្នុងការងារ និងមិនដែលធ្លាប់ឈប់សម្រាកពីមុនមក។

នៅចុងឆ្នាំ១៩៧៨ អង្គការបានជម្លៀសក្រុមគ្រួសារខ្ញុំទៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ នៅទីនោះ អង្គការបានបំបែកក្រុមគ្រួសាររបស់ខ្ញុំចេញពីគ្នា។ ខ្ញុំមានតួនាទីធ្វើកិច្ចការងារ ដូចគ្នាទៅនឹងកិច្ចការងារដែលខ្ញុំធ្លាប់ធ្វើនៅក្នុងភូមិខ្ទោកដែរ ប៉ុន្តែខុសគ្នានៅត្រង់អាហារហូបចុក ព្រោះចុងភៅបានយកអង្ករ២កំប៉ុង មកបបរនៅក្នុងខ្ទះត្នោតធំមួយ សម្រាប់ប្រជាជនហូបច្រើននាក់។ ដោយសារតែខ្ញុំគឺជាប្រជាជនមកពីតំបន់ភូមិភាគបូព៌ា ដូច្នេះពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំត្រូវរស់នៅជាមួយភាពភ័យខ្លាច។ អង្គការបានជម្លៀសខ្ញុំឲ្យទៅធ្វើការពីមួយកន្លែងទៅមួយកន្លែង ដូចជានៅសហករណ៍ភូមិជ្រៃ។ នៅតាមផ្លូវដែលខ្ញុំត្រូវទៅធ្វើការច្រូតស្រូវ ខ្ញុំបានឃើញមនុស្សប្រហែលជា២ ទៅ៣ នាក់ កំពុងជីករណ្តៅ។ ខ្ញុំបានខ្សឹបសួរអ្នកនៅក្នុងក្រុមថា គេជីករណ្តៅដើម្បីអ្វី ប៉ុន្តែអ្នកនៅក្នុងក្រុមរបស់ខ្ញុំបានប្រាប់ខ្ញុំថា កុំឲ្យខ្ញុំសួរផ្តេសផ្តាស។ នៅពេលល្ងាច ពេលដែលខ្ញុំត្រឡប់មកពីច្រូតស្រូវវិញ ខ្ញុំបានឃើញសាកសពមនុស្សនៅក្នុងរណ្តៅនោះ ព្រោះអ្នកជីករណ្តៅកប់សាកសពមិនបានជិតឡើយ។ ខ្ញុំឃើញជើងដៃរបស់សាកសពដែលមើលទៅគួរឲ្យសង្វេគ។ ពេលឃើញទិដ្ឋភាពបែបនេះ ខ្ញុំភិតភ័យយ៉ាងខ្លាំង ព្រោះខ្ញុំមិនធ្លាប់ឃើញហេតុការណ៍បែបនេះពីមុនមកទេ។ មិនយូរប៉ុន្មានខ្ញុំក៏ត្រូវបានបញ្ជូនឲ្យទៅជីកដីនៅស្រុកគាស់

ត្រឡប់។ ក្នុងទំហំដី១ហិកតា គឺពោរពេញទៅដោយសាកសពមនុស្ស។

នៅដើមខែមករា ឆ្នាំ១៩៧៩ នៅពេលកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមកដល់ខេត្តបាត់ដំបង ខ្មែរក្រហមបានកៀរប្រជាជនជាច្រើននាក់ឡើងទៅលើភ្នំ។ ឆ្លៀតឱកាសនោះ ខ្ញុំបានរត់ត្រឡប់មកក្រោយវិញ។ ខ្ញុំបានមករកឪពុកម្តាយខ្ញុំឃើញ រួចយើងបាននាំគ្នាវិលត្រឡប់មកស្រុកវិញ។ នៅតាមផ្លូវត្រឡប់មកផ្ទះ ខ្ញុំបានឃើញសាកសពជាច្រើន។ ខ្ញុំនិងក្រុមគ្រួសារ ដើរបានចម្ងាយ ៣០គីឡូម៉ែត្រក្នុងមួយថ្ងៃ សំដៅទៅកន្លែងយាមល្បាតរបស់កងទ័ពវៀតណាម ព្រោះវៀតណាមបានដាក់ពង្រាយកងទ័ពរបស់ខ្លួនពីមួយកន្លែងទៅមួយកន្លែង ចម្ងាយប្រហែល៣០គីឡូម៉ែត្រពីគ្នា។ ទម្រាំមកដល់ស្រុកកំណើត នៅភូមិកំពង់អាទុង សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង គឺខ្ញុំត្រូវចំណាយពេលកន្លះខែ។ ពេលមកដល់ស្រុកកំណើត បង ឈឹម បានមកប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំបានស្លាប់ហើយ នៅពេលដែលខ្មែរក្រហមជម្លៀសគាត់ទៅខេត្តបាត់ដំបង។ រឿងដែលធ្វើឲ្យខ្ញុំនឹកស្តាយស្រណោះនោះ គឺយើងមិនបានជួបគ្នានៅក្នុងខេត្តបាត់ដំបង ដោយសារតែខ្ញុំពុំបានដឹងថាប្តីរបស់ខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង។ ខ្ញុំបានរស់នៅជាស្ត្រីមេម៉ាយរហូតមកដល់សព្វថ្ងៃ។

# ស៊ូ យីម ៖ ខ្ញុំតែងតែនិយាយអំពីការបាត់ខ្លួនរបស់មីងពូ និងរឿងរ៉ាវរបស់ខ្ញុំប្រាប់ទៅកូនចៅ

ផន ចន្នី

ខ្ញុំឈ្មោះ ស៊ូ យីម ភេទស្រី អាយុ៦០ឆ្នាំ កើតនៅភូមិដានគោម ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត។ បច្ចុប្បន្នខ្ញុំរស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ ខ្ញុំមានឪពុកឈ្មោះ ស៊ូ គិត និងម្តាយឈ្មោះ នាង អ៊ីប។ ខ្ញុំគឺជាកូនទី១ក្នុងចំណោមបងប្អូនចំនួន១១នាក់ គឺស្រី៦នាក់ និងប្រុស៥នាក់។ ខ្ញុំមិនបានរៀនសូត្រនោះទេពីសង្គម ដោយសារក្រុមគ្រួសារខ្ញុំមានជីវភាពក្រីក្រ។ ខ្ញុំត្រូវនៅផ្ទះជួយធ្វើស្រែចម្ការឪពុកម្តាយ និងមើលប្អូនៗ។ ក្រោយមក ខ្ញុំត្រូវបានប្រធានកងខាងកងទ័ពរំដោះខ្មែរក្រហមចាត់ឲ្យធ្វើការងារនៅតាមកងចល័ត។



ស៊ូ យីម ភេទស្រី អាយុ៦០ឆ្នាំ រស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានធ្វើការងារជាកងនារី ដោយប្រធានកងនារីរបស់ខ្ញុំមានឈ្មោះ គ្រប់ ហើយបានបែងចែកខ្ញុំឲ្យមើលការងារនៅតាមកងកុមារ ដោយការងាររបស់ខ្ញុំពេលនោះគឺ ដើររើសអាចម៍គោនៅក្នុងភូមិដានគោម ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត រួមទាំងដើរកាត់ដើមទន្ទ្រានខែត្រចិញ្ច្រាំលាយជាមួយអាចម៍គោធ្វើជី រយៈពេល១៥ថ្ងៃ។ លុះដល់រដូវវស្សា ប្រធានកងនារីបានប្រើឲ្យក្រុមរបស់ខ្ញុំរែកជីដែលលាយរួចយកទៅដាក់តាមស្រែ និងយកជីនោះទៅដាំដំឡូងជ្វា និងដាក់

ដំណាំផ្សេងៗទៀត។ លុះមកដល់ឆ្នាំ១៩៧៨ ខ្ញុំបានចូលធ្វើការងារនៅកងចល័តវិញ គឺកងចល័តនារីនៅអន្លង់ទៀន ស្រុកកោះអណ្តែត ខេត្តតាកែវ។ ខ្ញុំជីកប្រឡាយ និងលើកទំនប់រហូតដល់ស្រុកកោះអណ្តែត ខេត្តតាកែវ។

ចំពោះរបបហូបចុក គឺហូបបបរអង្ករ២កំប៉ុងជាមួយនឹងសម្លព្រលឹតសម្រាប់មនុស្ស១០នាក់។ ខ្ញុំចាប់ផ្តើមធ្វើការងារចាប់ពីម៉ោង៤ទៀបភ្លឺរហូតដល់ម៉ោង១២ថ្ងៃត្រង់ និងចាប់ពីម៉ោង១រសៀលរហូតដល់ម៉ោង៥ល្ងាច ទើបសម្រាកងូតទឹក បន្ទាប់មកហូបបបរ។ រីឯការស្លៀកពាក់វិញគឺមានតែអាវ និងសំពត់ខ្មៅ ចាស់ៗ២សម្រាប់និងក្រមាមួយប៉ុណ្ណោះ។ ខ្មែរក្រហមតម្រូវឲ្យខ្ញុំកាត់សក់ត្រឹមក។

ខ្ញុំធ្វើការនៅកងចល័តនារីរហូតដល់ឆ្នាំ១៩៧៩ ក៏មានគ្រាប់ផ្លោងរបស់កងទ័ពវៀតណាមសំដៅមកលើប្រជាជនខ្មែរនៅតំបន់ភ្នំខ្វាម និងភ្នំសំបុកមាន់ ខាងកើតស្រុកកោះអណ្តែត ខេត្តតាកែវ។ នៅពេលមានការផ្លោងគ្រាប់ និងផ្ទុះអាវុធ ខ្ញុំក៏រត់ត្រឡប់មកស្រុកកំណើត។ បន្ទាប់មកខ្ញុំក៏រត់បន្តទៅនៅលើភ្នំនារាយណ៍ ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។ ខ្ញុំបានជួបឪពុកម្តាយ បងប្អូន និងក្រុមគ្រួសារនៅទីនោះ។ ចំណែកកងទ័ពវៀតណាមបានវាយប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមរហូតជិតដល់ក្រុងកំពត។

នៅពេលនោះ ខ្ញុំរួមជាមួយឪពុកម្តាយ និងបងប្អូនបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ។ រហូតដល់ឆ្នាំ១៩៨២ ទើបខ្ញុំរៀបការជាមួយប្តី និងប្រកបមុខរបរធ្វើស្រែចម្ការរហូតដល់សព្វថ្ងៃ។ ទោះបីយ៉ាងណា ខ្ញុំនៅតែឈឺចាប់ព្រោះធ្លាប់បានឆ្លងកាត់ការលំបាក ហើយក៏គ្មានថ្ងៃបំភ្លេចបានដែរ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បងប្អូនម្នាក់ឈ្មោះ សុខ និងមីងម្នាក់ឈ្មោះ អែម។ មីងពូរបស់ខ្ញុំធ្វើការងារនៅកងចល័ត។ បន្ទាប់ពីអ្នកទាំងពីរបាត់ខ្លួន ខ្ញុំបានទៅសួរកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមឆ្លើយតបថា កុំបារម្ភអ្នកទាំងពីរ (មីងពូរបស់ខ្ញុំ) មិនទៅណាទេ ពេលនេះពួកគាត់បានក្លាយជាសមាជិកពេញសិទ្ធិរបស់អង្គការ ហើយកុំគិតច្រើនសំខាន់ខិតខំធ្វើការងារជូនអង្គការទៅប្រសើរជាងគិតអីផ្តេសផ្តាស។

រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំមិនដែលបានទទួលដំណឹងពីពួកគាត់ទេ។ ខ្ញុំតែងតែនិយាយអំពីការបាត់ខ្លួនរបស់មីងពូ និងរឿងរ៉ាវរបស់ខ្ញុំប្រាប់ទៅកូនចៅ និងក្មេងជំនាន់ក្រោយឲ្យបានដឹង និងបានយល់អំពីប្រវត្តិតស៊ូរបស់ខ្ញុំក្នុងអំឡុងពេលសម័យសង្គ្រាម។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញទេ។

ស៊ូ យឹម ផ្តល់បទសម្ភាសន៍អំពីបញ្ហាប្រឈមទាក់ទងនឹងសុខភាព និងរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមដល់ក្រុមអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅភូមិបាក់នឹម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



«ទួលពិឃាដ» (តចប់)

# ១៩. វិញ្ញាណសុបិន

## បែកធ្លាយដំណឹងពីរបៀបសម្លាប់ឪពុកម្តាយ និង ប្អូនភ្លោះខ្ញុំ ព្រាយបិសាចខ្មៅ ស្រុកឈាមជាតិឯង

...មានខ្សែស្រឡាយចិន និងជនជាតិចាមផងដែរ។ ដោយមនុស្សចាស់គេប្រើគល់ ឫស្សី ត្បូងចប ក្តៅរទេះវាយកញ្ចឹងកទម្លាក់ចូលក្នុងអណ្តូង និងរណ្តៅ ចំណែកកូនក្មេង និងទារកពួកគេចាប់ជើងបោកផ្ទប់នឹងគល់ត្នោត ឬពួកវាបោះទារកទៅលើ ហើយយកចំពុះទួងទ្រពីក្រោមជាការសម្លាប់លេងសើច។

អ្នកខ្លះបានស្លាប់ពីមាត់អណ្តូង តែអ្នកខ្លះមិនទាន់ស្លាប់នៅសល់ដង្ហើមបង្រិត ខំប្រឹងវារពីរណ្តៅ តែពួកកងឈ្លប ទាំងនោះចាប់វាយនឹងគល់ឫស្សីបន្ថែមរហូតដល់ដាច់ខ្យល់ស្លាប់។ មើលទៅគួរឲ្យអាណោចអាធ័មវេទនាជាពន់ពេក លាយឡំនឹងសំនៀងសំឡេងចម្រៀងបដិវត្តន៍ជាបទភ្លេងក្នុងខែកហែកលោកឲ្យក្រវ័យខ្លោចផ្សាដិតដាមក្នុងអារម្មណ៍បន្ទិតាមខគ្សោ សនសព្ទបើកបំពងដើម្បីបន្ទំនូវសំឡេងស្រែកថ្ងូរទូញសោកនឹងការឈឺចាប់ខ្លោចផ្សានេះ។

(ទាំងនេះជាសម្តីរបស់អ្នកភូមិចាស់ៗមានអ្នកឡើងត្នោតអ្នកចាំគោក្របី នៅក្បែរទួលស្លាំងតំណាលឲ្យស្តាប់ ហើយខ្ញុំក៏ដឹងខ្លះៗ ដែរ និងយោងតាមឯកសារស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១៨០៨០១។)

ផែនការពួកគេសម្លាប់ចាប់ផ្តើមពីពេលព្រលប់ៗដល់យប់ឲ្យអស់តែម្តង។ ពេលថ្ងៃចាប់ផ្តើមជីករណ្តៅបន្ត។ បើមានកម្មាភិបាលមកថ្មី គឺសម្លាប់ពួកចាស់ចោល ដោយយប់នេះសម្លាប់គេ យប់ស្អែកគេសម្លាប់វិញ ដើម្បីបំបិទដានក្នុងរបបនយោ-បាយស្រែកឈាម សម្លាប់! សម្លាប់! សម្លាប់!។ ទិដ្ឋភាពដែលយើងធ្លាប់តែឮនៅក្នុងសម័យ ហ៊ីត្លែរ។

***របត់នយោបាយ និងមនោគមវិជ្ជាអង្គការបដិវត្តន៍មហាវិនាសកម្មដែលបានសាងឡើងរបស់ពួកអាវខ្មៅខ្មែរក្រហមពិតជាសាហាវព្រៃផ្សៃយង់ឃ្នងណាស់។***

***ទង្វើនេះបានធ្វើឲ្យប្រជាជនខ្មែរទាំងមូលគ្មានការទុកចិត្តគ្នារវាងឪពុកម្តាយ បងប្អូនកូនក្មួយ ក្នុងការតាមដានគ្នាទៅវិញទៅមក។ បងស្អប់ប្អូន កូនស្អប់ឪពុកម្តាយដែលមានអង្គការជាម៉ែឪថ្មី រហូតឈានទៅរកការកាប់សម្លាប់គ្នា ជាវប្បធម៌លេសមួយលើកទឹកចិត្តដល់ជនដៃដល់ដែលហ៊ានលើកដៃសម្លាប់ប្រជាជនស្លូតត្រង់ គឺជាជនអស្ចារ្យ ឈានមុខគេ ហើយបានទទួលជ័យជម្នះ ឈរលើកពាន គ្រវីទង់ បាតដៃប្រឡាក់ឈាម ហើយស្រែកខ្លាំងៗថា ជយោបដិវត្តន៍ មហាលោតផ្លោះ មហាអស្ចារ្យ លើគំនរសាកសព ភ្នំឆ្អឹងសមុទ្រឈាម ស្រែកឃ្លានហុតឈាមជាតិឯង សាងបាបកម្មក្នុងភក់ជ្រាំនៃលទ្ធផលអសោចក្រោមសូន្យ ហើយចង់សួរទៅថ្នាក់ដឹកនាំទាំងនោះថា "ប្រសិនបើ សម្លាប់ប្រជាជនឈាមខ្មែរឯងអស់ហើយ តើមានផែនការបែបណាទៀត?"***

***មេដឹកនាំខ្មែរក្រហមបានធ្វើការកែប្រែប្រវត្តិសាស្ត្របញ្ច្រាសទិស ដើម្បីឆ្លុះបញ្ចាំងពីជ័យជម្នះលើផេះផង់ និងការផ្លាស់ប្តូរផ្នត់គំនិតក្នុងសង្គមចាស់ មានទាំងវប្បធម៌ ភាសាអក្សរសាស្ត្រ ជាភាសាសរសេរនិងភាសានិយាយ ដែលមនុស្សលោកមិនយល់ទាល់តែសោះ។***



ទិដ្ឋភាពតំណាង៖ កងឈ្លបបណ្តើរប្រជាជនថ្មីដទៃទៀតមកសម្លាប់។ (ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឱ! អ្នកម្តាយ

## ដង្ហើមចុងក្រោយនៃសម្រែកទុក្ខបៀមខ្ទុះ ឈាមបដិវត្តន៍

ឱ! អ្នកម្តាយមានគុណនិងជាទីស្រឡាញ់របស់កូនអើយ ហេតុអ្វីកម្មវេរាតាមលងអន្ទងអ្នកម្តាយមិនចេះចប់សោះ។ ម៉េចមិនហោះរំលងឲ្យផុតពីអ្នកម្តាយទៅ? ខ្ញុំមិនដឹងថាអ្នកម្តាយខ្ញុំវាបានធ្វើបាបវេទនាប៉ុនណាទេ! នឹងការប្រគាយប្រគប់គ្នានៅក្នុងអណ្តូងនោះ។ វាមានកាំភ្លើង ឯម្តាយខ្ញុំដៃទទេ ហើយត្រូវគេចងមុខទៀតនៅលើសាកសពខ្លះដែលពួកវាសម្លាប់ទម្លាក់ទៅមុន។

ខ្ញុំដឹងថា អ្នកម្តាយពិតជាមានកំហឹងឈឺចាប់យ៉ាងខ្លាំងដែលមិនអាចស៊ូទ្រាំឱនក្បាលឲ្យកងឈ្លបទាំងនោះវាយសម្លាប់មកលើប្តីកូនៗដោយងាយនោះទេ។ គាត់ប្រែក្លាយការឈឺចាប់បៀមទុក្ខសោក ខ្ទុះឈាមទាំងប៉ុន្មានដែលទុកជាយូរមកហើយ។

ដល់ពេលវេលាហើយ! អំណាចតែស្លាប់ដាច់ខាត ត្រូវតែហ៊ានតដៃបូជាជីវិតជម្រះបញ្ជីចាស់ រហូតហ៊ានប្រទូស្តវាយគ្នាចាប់ទាញយកកងឈ្លបម្នាក់លោតចូលទៅក្នុងអណ្តូងជាមួយ។ ទោះដឹងថា ចុងក្រោយពួកគេសម្លាប់គាត់ក្នុងរូបភាពយ៉ាងណាក៏ដោយ។

**ពិតប្រាកដណាស់ ព្រាយបិសាចខោអាវខ្មៅកំពុងសម្លាប់ម្តាយក្រោមនឹមទឹកភ្នែកអង្គការបដិវត្តន៍ ដែលហូរជាជលសា ដង្ហោយហៅ និងលាឪពុកម្តាយ ប្តី កូនៗ ចង់ប្រាប់ថា ពេលនេះត្រូវគេសម្លាប់ឲ្យរលត់ជីវិត ដោយការឈឺចាប់ជាទីបំផុត។ ឱ! កម្មកំណាចកម្ទាយគ្រួសារខ្ញុំឲ្យព្រាត់ប្រាសគ្នា ព្រាត់ព្រោះខ្មែរក្រហមចិត្តឫស្យា ប្រហារដួងចិត្តឲ្យព្រួយ ជីវិតប្រៀបដូចផ្ការលួសត្រូវខ្យល់បក់រលួយ សូមព្រះលោកជួយ បើកើតជាតិក្រោយវេញខ្សែជីវិតរស់ជួបជុំគ្រួសារបានសុខក្សេមក្សាន្ត។ ស្មាលារបបខ្មៅនេះគ្រប់ៗជាតិ។**

អ្នកម្តាយជាទីស្រឡាញ់ស្មើជីវិតរបស់កូនអើយ ឲ្យកូនសូមអភ័យទោសផងចំពោះមុខព្រលឹងទឹកភ្នែកម្តាយដែលកូនបានឮដំណឹងដ៏អកុសលនេះ ហើយមិនអាចជួយ និងមិនបានតបស្នងសងគុណដល់អ្នកមានគុណទាំងទ្វេ។ បើមានជាតិក្រោយមែនកូននឹងសុំតបស្នងសងគុណដល់លោកពុកអ្នកម្តាយជាទីស្រឡាញ់។



ទិដ្ឋភាពតំណាល៖ វិធីពួកកងឈ្លបសម្លាប់ក្មេងៗ រួមទាំងប្អូនភ្លោះរបស់ខ្ញុំ ដោយបោកផ្ទប់សម្លាប់នឹងគល់ត្នោត និងលើកបោះទៅលើដោយយកចំពុះទុងចាក់ទ្រូពីក្រោមគួរឱ្យសាហាវជាពន់ពេក រួចទើបបោះចូលក្នុងរណ្តៅជាក្រោយ។
(ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្យ៉ាងវិញទៀត កូននៅតែស្រណោះពាក្យសម្តីម្តាយដែលបាននិយាយប្រាប់បងស្រី មុនគេយកអ្នកម្តាយទៅសម្លាប់ថា "ចិន្តាកូនស្រី ចូលកូនប្រាប់បងវុឌ្ឍឯងនៅឯសមរភូមិមុខជាកងចល័តឲ្យដឹងផងថា ម្តាយឪពុកនិងប្អូនភ្លោះ វិសុទ្ធ វិសាល អង្គការឲ្យទៅនៅទួលស្លាំងហើយ"។

មកដល់ពេលនេះតើព្រលឹងអ្នកម្តាយមានបានដឹងទេថា បងប្រុសវុឌ្ឍិ កូនរបស់ម្តាយ ក៏ត្រូវគេវាយសម្លាប់ទម្លាក់ចូលក្នុងរណ្តៅក្នុងថ្ងៃតែមួយជាមួយឪពុកម្តាយនៅឯសមរភូមិមុខកងចល័តក្នុងវត្តភូមិកញ្ចាំដែរ។ ពេលនេះព្រលឹងអ្នកទាំងពីរប្រហែលគិតថាបងប្រុសវុឌ្ឍបាននៅរួមរស់ជាមួយប្អូនៗ។ ខ្ញុំដឹងថា ម្តាយពិតជាអាឡោះអាល័យកូនវុឌ្ឍិខ្លាំងណាស់ ដោយបែកពីកូនរាប់ខែ មិនបានឃើញមុខរហូតត្រូវគេសម្លាប់។

ចំណែកព្រលឹងបងវុឌ្ឍិក៏មិនខុសពីព្រលឹងអ្នកម្តាយដែរ ប្រហែលគិតថា ឪពុកម្តាយនិងប្អូនៗ បានរស់ជួបជុំគ្នាហើយមើលទៅ។ ពិតជាសម្រែកព្រលឹងកកឈាមក្នុងវិញ្ញាណគ្មានកោះត្រើយនៃរលកឆាកជីវិតគ្រួសារក្រឡាប់ចាក់មួយនេះ។

ម្យ៉ាងទៀតមុនពេលគេសម្លាប់ ត្រូវចាប់ម្តាយបំបែកពីរកូនភ្លោះ និងប្តីដោយកូនភ្លោះសម្លាញ់របស់ម្តាយត្រូវបានពួកកងឈ្លបអាចចាប់ជើងបោកផ្ទប់សម្លាប់នឹងគល់ត្នោតហូរឈាមធ្លាយខួរ និងអាចលើកបោះទៅលើ ហើយយកចំពុះទុងចាក់ទ្រពីក្រោមរួចទើបទម្លាក់ចូលទៅក្នុងអណ្តូងតាមក្រោយ។



*ទិដ្ឋភាពតំណាងៈ កងឈ្លបខ្មែរក្រហមកាប់សម្លាប់ឪពុកខ្ញុំ*
*(ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ចំណែកឪពុកត្រូវពួកកងឈ្លបអាវខ្មៅចងមុខ និងចងស្លាបសេកបណ្តើរយកទៅវាយកាប់សម្លាប់រួចទម្លាក់ចូលក្នុងរណ្តៅដ្យេងគួរឲ្យអាណោចអាធ័មជាទីបំផុតសម្រាប់មនុស្សស្លូតត្រង់ ហើយជាអ្នកបួសទៀតៗ។ ពួកខ្មែរក្រហម ពិតជាចិញ្ចឹមចិត្តតាមផ្តន្ទានឹងគ្រួសារខ្មែរណាស់។ ពេលនោះក្នុងចិត្តម្តាយប្រាកដជាបែងចែកជាមួយពាន់ចម្រៀក និងស្រាវាស្រទេញខ្លាំងណាស់ពិតជាធ្វើឲ្យគាត់ស្លាប់ចិត្តមុនពេលគេបោកគ្រាប់បែកសម្លាប់។

**ឱ! មេកងសយកម្មាភិបាលខ្មែរក្រហមអើយ! ម្តេចអ្នកមិនប្រណីដល់ក្រុមគ្រួសារខ្ញុំនិងប្រជាជនទាំងប៉ុន្មាននោះផង?**

រឿងរ៉ាវទាំងអម្បាលម៉ានដែលខ្ញុំនិងបងស្រីបានឮ បានដឹង ពិតជារន្ធត់ ស្លុតអារម្មណ៍ ចាក់ដោតក្នុងក្រអៅបេះដូង ប្រៀបបានយកពូថៅពុះទ្រូងឲ្យធ្លាយ សោកសៅ ប៉ោកប្រាណ រុញច្រានដួងចិត្ត ឲ្យស្ថិតនៅក្នុងភ្នក់ភ្លើងជីវិត។ ធ្វើឲ្យខ្ញុំនិងបងស្រីហាយំលែងចេញ ដង្ហោយហៅព្រលឹងវិញ្ញាណមានទាំងរូបរាងនៅច្បាស់នឹងភ្នែក។ ចុះកម្មពៀរអ្វីមកផ្តន្ទាគ្មានលស់ពេលល្ហែ នៅក្នុងខ្សែជីវិតគ្រួសារបរិសុទ្ធមួយនេះ។

ហ៊ឹះ ពិតជាអន្ទង់កម្មនៃជីវិតទឹកភ្នែកឈាមស្រស់មែន។ តើអារម្មណ៍ដួងចិត្តរន្ធត់ប៉ុនណា នូវគុកកម្មផ្លូវចិត្តប្រចាំរូបកាយនៃគ្រួសាររបស់ខ្ញុំ ដូច្នេះ? ព្រលឹងលោកឪពុកអ្នកម្តាយ ប្រាកដជាហោះហើរវិលវល់ក្នុងវដ្តសង្សារគ្មានកោះគ្មានត្រើយរកទីបញ្ចប់គ្មាន។ អ៊ីៗ នៃកម្មវេរារឿងគ្រួសារព្រាត់ស្លាប់ទាំងទឹកភ្នែកក្នុងឆាកល្ខោនទណ្ឌកម្មជីវិតឥតមេត្តាម ហាធំធេងត្រូវបានបញ្ចប់យ៉ាងសោកសៅ ជាទីបំផុតក្នុងប្រវត្តិសាស្ត្រអាក្រក់ជូរជាតិនៅលើទួលស្វាំង (ទួលស្លាប់) នៃការរស់នៅក្នុងគុកទារុណ្ឌកម្មរបស់អង្គការបដិវត្តន៍បីឆ្នាំប្រាំខែម្ភៃថ្ងៃរហូតដល់ថ្ងៃស្លាប់។

ចាប់ពីពេលនេះទៅកូនៗ មានទុក្ខឥតល្ហែនឹករលឹក លោកឪអ្នកម៉ែដែលបានលាលុះរលត់ផុតសង្ខារ ហើយស្រែកយំខ្លែងៗលើបង្គងកម្សត់ សែនអាល័យ យំទាល់តែទឹកភ្នែកហូតពីឱរា នៃវាសនាជីវិតកូនកំព្រា។

កូនៗ សូមឧទ្ទិសដល់ព្រលឹងលោកទាំងពីរ បងប្រុស និងប្អូនក្មេងបានស្ងប់សុខក្នុងឋានសុគតិភពចុះ។



រូបភាពបច្ចុប្បន្ន២០១៩៖ ភូមិក្រាំងមើលពីម្ខាងបឹង។
(ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបភាពបច្ចុប្បន្ន២០១៩៖ ក្នុងទួលស្វាំង។
(ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡុង វង្សសមិទ្ធ

រូបក្របមុខ៖
អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកអន្លង់វែងរង់ចាំពិនិត្យសុខភាព
ជាមួយក្រុមគ្រូពេទ្យជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់
ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 285, September 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.